

# សិទ្ធិមនុស្សនៅកម្ពុជាៈ
# ស្ថិរភាព ដែលមើលឃើញតែពីខាងក្រៅ

“ មនុស្សមួយចំនួនតូចបានយល់ច្រឡំលើបញ្ហានេះ
ហើយចំនួនតិចតួចក្នុងចំណោមនេះយល់ច្រឡំយូរបន្តទៀត ”
ដោយៈ លោកអៀន ផតធី នាយកក្រុមធនាគារពិភពលោក

របាការណ៍ លីកាដូ
ខែកក្កដា ឆ្នាំ២០០៦


លីកាដូ
សម្ព័ន្ធខ្មែរជំរឿនិងការពារសិទ្ធិមនុស្ស លីកាដូ
LICADHO
Cambodian League for the
Promotion and Defense of Human Rights

# សិទ្ធិមនុស្សនៅកម្ពុជា:
# ស្ថិរភាព ដែលមើលឃើញតែពីខាងក្រៅ

"មនុស្សមួយចំនួនតូចបានយល់ច្រឡំលើបញ្ហានេះ
ហើយចំនួនតិចតួចក្នុងចំណោមនេះយល់ច្រឡំយូរបន្តទៀត"

ដោយ: លោកអៀន ផតធី នាយកក្រុមធនាគារពិភពលោក

---

របាការណ៍ លីកាដូ

ខែកក្កដា ឆ្នាំ២០០៦


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENCE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួនាទី ជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ នឹងឃ្លាំមើលរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១២ ខេត្ត-ក្រុងផ្សេងទៀត។

លីកាដូ កំពុងបន្តសកម្មភាពរបស់ខ្លួនតាមរយៈការិយាល័យកម្មវិធីទាំង ៧ របស់ខ្លួន ដូចខាងក្រោម:

- **ការិយាល័យឯកសារ និងធនធានព័ត៌មាន** គឺជាការិយាល័យ ដែលរក្សាចងក្រងសំណុំរឿងនៅក្នុងប្រព័ន្ធទិន្នន័យ ដើម្បីងាយស្រួលក្នុងការរកឯកសារ នឹងវិភាគអោយបានឆាប់រហ័ស។
- **ការិយាល័យអប់រំសិទ្ធិមនុស្ស**គឺជាការិយាល័យដែលបើកវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ក្រុមគោលដៅនានាដូចជា មន្ត្រីរាជការ សិស្ស និស្សិត ព្រះសង្ឃ ព្រមទាំងបើកវគ្គផ្សព្វផ្សាយសិទ្ធិមនុស្សដល់សាធារណៈជននានាថែមទៀតផង។
- **ការិយាល័យស៊ើបអង្កេត** គឺជាការិយាល័យដែលមានតួនាទីជាអ្នកស៊ើបអង្កេតករណីរំលោភសិទ្ធិមនុស្ស និងជួយជនរងគ្រោះនានា ក្នុងដំណើរការបណ្តឹងដែលពាក់ព័ន្ធខាងផ្នែកច្បាប់។ បុគ្គលិកដែលមានការហ្វឹកហ្វឺនជំនាញត្រឹមត្រូវ ក៏បានឃ្លាំមើលពន្ធនាគារចំនួន ១៨ ដើម្បីវាយតម្លៃស្ថានភាពពន្ធនាគារ ព្រមទាំងជួយអោយពិរុទ្ធជនទាំងឡាយទទួលបាននូវតំណាងផ្នែកច្បាប់ទៀតផង។
- **ការិយាល័យពេទ្យ** គឺជាការិយាល័យដែលផ្តល់សេវាវេជ្ជសាស្ត្រដល់ពិរុទ្ធជន ទណ្ឌិត និងមន្ត្រីពន្ធនាគារនៅតាមពន្ធនាគារចំនួន ១៨ កន្លែង។ ក្រៅពីនេះ ក៏បានផ្តល់សេវាវេជ្ជសាស្ត្រ និងជួយបញ្ជូនជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទៅមន្ទីរពេទ្យផងដែរ។
- **កម្មវិធីប្រឆាំងនឹងទារុណ្ណកម្ម** ជាការិយាល័យផ្តល់ សេវាកម្មស្តារលទ្ធភាពទូទៅដល់ជនរងគ្រោះដោយអំពើទារុណ្ណកម្ម និងធ្វើការតស៊ូមតិប្រឆាំងនឹងអំពើ ទារុណ្ណកម្ម។
- **ការិយាល័យសិទ្ធិកុមារ** ជាការិយាល័យដែលផ្តល់ការអប់រំសិទ្ធិកុមារដល់សាធារណៈជនទូទៅ ស្ថាបនាបណ្តាញការពារកុមារនៅតាមមូលដ្ឋាននានា និងស៊ើបអង្កេតការរំលោភសិទ្ធិកុមារ ។
- **ការិយាល័យសិទ្ធិស្ត្រី** ជាការិយាល័យអប់រំសិទ្ធិស្ត្រីដល់សាធារណៈជនទូទៅ ស៊ើបអង្កេតការរំលោភសិទ្ធិស្ត្រី និងធ្វើការតស៊ូមតិ ដើម្បីអោយមានការផ្លាស់ប្តូរផ្នែកច្បាប់ និងសង្គម។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង៖**

លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការលីកាដូ

អាសយដ្ឋាន៖ អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦, ផ្លូវលេខ ៩៩, រាជធានីភ្នំពេញ, កម្ពុជា

ទូរស័ព្ទ៖ (៨៥៥) ២៣ ៣៦០ ៩៦៥ / ៣៦៤៩០១ , ទូរសារ៖ (៨៥៥) ២៣ ៣៦០ ៩៦៥ / ២១៧ ៦២៦

អ៊ីម៉ែល៖ contact@licadho.org     គេហទំព័រ៖http://www.licadho.org/

# មាតិការឿង


| | |
|---|---|
| សេចក្តីផ្តើម | ១ |
| ដីធ្លី | ៤ |
| សេរីភាពប្រជាធិបតេយ្យថមថយ | ១១ |
| និទ្ទណ្ឌភាព | ១៨ |
| ប្រព័ន្ធតុលាការ | ២៤ |
| តួនាទីរបស់សហគមន៍អន្តរជាតិ | ៣១ |
| អនុសាសន៍ | ៣៥ |
| សេចក្តីសន្និដ្ឋាន | ៣៦ |

# សេចក្តីផ្តើម

ចំណងជើងកាសែតជាច្រើន បានសរសេរពីក្តីសង្ឃឹមល្អស្តីពីជីវភាពរស់នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ ដែលធ្វើឱ្យយល់ច្រឡំទៅនឹងស្ថានភាពជាក់ស្តែងថាៈ កំណើនសេដ្ឋកិច្ច ១៣% ក្នុងឆ្នាំ ២០០៥ និងការផ្ទុះផ្សាដ៏យូរលង់រវាងគូរបដិបក្ខខាងនយោបាយ ។

ការពិត គឺស្ថិតនៅក្នុងសភាពអ័ព្ទអួរ ស្រពិចស្រពិលយ៉ាងខ្លាំង ។

ស្ថិតនៅក្រោមស្ថិរភាពនយោបាយ និងអភិវឌ្ឍន៍សេដ្ឋកិច្ច ពលរដ្ឋកម្ពុជាភាគច្រើននៅតែទទួលរងគ្រោះដោយឥតឈប់ឈរ ។

ប្រជាពលរដ្ឋកម្ពុជាមួយភាគធំ កំពុងរងគ្រោះពីអំពើរំលោភសិទ្ធិមនុស្សកាន់តែខ្លាំងឡើងៗ ដែលការរំលោភនោះភាគច្រើន ជាទង្វើរបស់មន្ត្រីរាជការមួយចំនួនជាអ្នកប្រព្រឹត្ត ដូចជា នគរបាល និង យោធាជាដើម ។ ចំណែកឯការដោះស្រាយរកយុត្តិធម៌ពីសំណាក់តុលាការកម្ពុជា ដែលល្បីខាងពុករលួយ និងលំអៀងទៅរកខាងនយោបាយនោះ គឺទទួលបាននូវយុត្តិធម៌តិចតួចបំផុត ។ ទំនាស់ដីធ្លីកើតឡើងពីការទាមទារដីកម្មសិទ្ធិឯកជន ឬដីសម្បទានសេដ្ឋកិច្ចធំៗ កំពុងបណ្តេញប្រជាពលរដ្ឋរាប់ពាន់គ្រួសារចេញពីផ្ទះសម្បែងរបស់ពួកគេជារៀងរាល់ឆ្នាំ ដែលធ្វើអោយពលរដ្ឋទាំងនោះ ជួបប្រទះនូវការខ្វះខាតដូចជាការអប់រំ សេវាកម្មសុខភាព និងសេវាកម្មសំខាន់ៗផ្សេងទៀត ក្នុងខណៈពេលដែលពួកគេជួបប្រទះនូវភាពក្រីក្រ និងការលំបាកកាន់តែខ្លាំងឡើងថែមទៀត ។

មន្ត្រីនគរបាល និងតុលាការកម្ពុជាខ្លះ ដែលបានប្រព្រឹត្តអំពើពុករលួយ និងនិទ្ទណ្ឌភាព ដែលក្នុងកិច្ចការជាប្រចាំរបស់ពួកគេ មិនអាចផ្តល់យុត្តិធម៌អោយជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សបានឡើយ ។

ការដោះលែងមេដឹកនាំសង្គមស៊ីវិលប្រាំរូប ដែលត្រូវបានចាប់ខ្លួនក្រោមបញ្ជារបស់លោកនាយករដ្ឋមន្ត្រី កាលពីខែ មករា ឆ្នាំ ២០០៦ ដោយចោទពីបទបរិហារកេរ្តិ៍ និងបទផ្សេងៗទៀត ត្រូវបានសហគមន៍អន្តរជាតិមួយចំនួនយល់ឃើញថា ជាសញ្ញាល្អប្រសើរឡើងវិញខាងផ្នែកសិទ្ធិមនុស្សនៅកម្ពុជា ។ ចំណុចនេះ វាមិនមែនជាការពិតទាំងស្រុងឡើយ ។ ថ្វីត្បិតបើ យើងស្វាគមន៍និងការដោះលែងនោះ ប៉ុន្តែធាតុពិត នៃការចាប់ខ្លួន គួរតែមិនអាចឱ្យកើតមានសោះឡើយ ។ ម្យ៉ាងទៀតការចោទប្រកាន់នៅតែមានបន្តលើសកម្មជនសិទ្ធិមនុស្សទាំងប្រាំរូប ដែលបាននាំអោយមានផលប៉ះពាល់យ៉ាងខ្លាំង និងយូរអង្វែងដល់សេរីភាពក្នុងការបញ្ចេញមតិ និងអ្នកខ្មែរគំនិតនៅកម្ពុជា ។

ឱកាសសំរាប់អនុវត្តសកម្មភាពលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា គឺជាលទ្ធផលល្អមួយដែលសង្គមស៊ីវិល និងអង្គការមូលនិធិនានាខិតខំប្រឹងប្រែងបំពេញអស់រយៈពេលជាងមួយទសវត្សកន្លងមក ត្រូវបានថមថយដោយរងការវាយប្រហារយ៉ាងធ្ងន់ធ្ងរមកលើសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាពក្នុងការជួបប្រមូលផ្តុំគ្នា ។ អំណាច និងទ្រព្យសម្បត្តិធនធានរបស់ប្រទេសបានធ្លាក់ទៅក្នុងដៃមនុស្សមួយចំនួនតូច ដែលប្រើប្រាស់តួនាទី ដើម្បីពង្រីក នឹងប្រមូលផ្តុំនូវបុព្វសិទ្ធិសំរាប់ផលប្រយោជន៍ខ្លួនឯង ដែលធ្វើឱ្យប៉ះពាល់ដល់ជនក្រីក្រ ។

ស្ថានភាពនយោបាយនៅកម្ពុជានាពេលបច្ចុប្បន្ន គឺជាលទ្ធិប្រជាធិបតេយ្យមួយដែលស្ថិតនៅក្នុងស្ថានភាពមិនច្បាស់លាស់ ។

រដ្ឋាភិបាលត្រូវបានបង្កើតឡើងចេញពីការបោះឆ្នោត ប៉ុន្តែ តើលទ្ធិប្រជាធិបតេយ្យអាចកើតឡើងនៅក្នុងបរិបទនៃការបំភិតបំភ័យបានដែរទេ? ការគាបសង្កត់លើសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពក្នុងការជួបប្រមូលផ្តុំគ្នាដែល មានលក្ខណៈនីតិរដ្ឋតិចតួច។ ការបោះឆ្នោតតែមួយមុខគត់ មិនអាចនាំអោយមានលទ្ធិប្រជាធិបតេយ្យ ឯករាជ្យភាពតុលាការប្រកបដោយសមត្ថភាព និងស្ថាប័នប្រជាធិបតេយ្យ ដើម្បីធានាដល់ការទទួលខុសត្រូវរបស់រដ្ឋាភិបាលបាននោះទេ ហើយទាំងនោះ គឺជាធាតុផ្សំយ៉ាងសំខាន់ ដែលបាត់ពីលទ្ធិប្រជាធិតេយ្យនៅកម្ពុជា។ បញ្ហាទាំងនេះ បានមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ហើយកង្វះខាងផ្នែកកែទម្រង់ដ៏សមស្រប គឺជាកង្វះឆន្ទៈនយោបាយ ដើម្បីអោយមានការផ្លាស់ប្តូរ។ ប្រជាជាតិកម្ពុជាមានការខ្វះខាតនូវគ្រឿងផ្សំពីរ ដែលមានសារៈសំខាន់ជាអាយុជីវិត, បញ្ហាជាច្រើនទាំងពីរ គឺមានអន្តរទំនាក់ទំនង ។

បន្ទាប់ពីទស្សវត្សនៃជម្លោះ និងសោកនាដកម្ម ជាញឹកញាប់ស្ថិរភាពកម្ពុជា ត្រូវបានគេយល់ថាជាស្ថិរភាពដោយគ្មានសង្គ្រាម ហើយពលរដ្ឋបានធូរស្រាលក្នុងចិត្ត ដោយរស់នៅក្នុងសុខសន្តិភាព។ ប៉ុន្តែ ស្ថិរភាពដ៏ជាក់លាក់ត្រូវតែធានាដោយលទ្ធិប្រជាធិបតេយ្យពិតប្រាកដសុទ្ធសាធ រួមទាំងការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋសម្រាប់មនុស្សគ្រប់រូប។ បើគ្មានយុត្តិធម៌ជាមូលដ្ឋានទេនោះ សេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋកម្ពុជា ដើម្បីអោយមានពហុបក្ស ការសន្តោសប្រណី និងសមធម៌សង្គមមិនអាចសម្រេចបានឡើយ។ ផ្ទុយទៅវិញ មានតែការកើនឡើងនូវគ្រោះថ្នាក់ដោយសារអស្ថិរភាពនយោបាយ សង្គម និងសេដ្ឋកិច្ច ដោយបញ្ឆេះឡើងពីអ្នកទោមនស្សទាំងឡាយ ដែលទទួលរងការរំលោភពីសំណាក់រដ្ឋ។

ចាប់តាំងពីមានកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ប្រទេសកម្ពុជា បានយល់ព្រមអនុវត្តតាមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗទាំងអស់ ក៏ដូចជាពិធីសារជាច្រើន និងអនុសញ្ញាដទៃទៀត ។ ប៉ុន្តែ ទោះបីជារដ្ឋាភិបាលកម្ពុជារំលោភលើកាតព្វកិច្ចផ្នែកសិទ្ធិមនុស្សរបស់ខ្លួនជាប្រចាំក៏ដោយ សហគមន៍អន្តរជាតិហាក់ដូចជាមានការរារែកក្នុងការនិយាយ ។ ម្ចាស់ជំនួយពហុភាគី និងទ្វេភាគីបានផ្តល់ប្រាក់រាប់កោដិដុល្លារ ដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍របស់កម្ពុជា ប៉ុន្តែការជាអន្តរជាតិនូវសូចនាករសិទ្ធិមនុស្សជាមូលដ្ឋាន រួមមានសុខភាព ការអប់រំ និងការកាត់បន្ថយភាពក្រីក្របង្ហាញថាប្រាក់ និងផែនការភាគច្រើនរបស់ពួកគេត្រូវបានរារាំងដោយអំពើពុករលួយ និទ្ទណ្ឌភាព និងកង្វះខាតឆន្ទៈនយោបាយ ដើម្បីធ្វើការកែទម្រង់ ។

កិច្ចខិតខំប្រឹងប្រែងអន្តរជាតិ ដើម្បីធ្វើអោយរដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវចំពោះការបរាជ័យទាំងនេះត្រូវបានធ្វើអោយភ័ន្តច្រឡំ និងពុំមានយន្តការអនុវត្តប្រកបដោយអត្ថន័យ ដើម្បីធានានូវការគោរពតាមច្បាប់អន្តរជាតិ និងគោលដៅរបស់មូលនិធិម្ចាស់ជំនួយឡើយ ។

ទោះបីជាមានការបរាជ័យរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តន៍តាមលក្ខខណ្ឌនៃសូចនាករត្រួតពិនិត្យរួមគ្នាសំរាប់ឆ្នាំ២០០៥ ដែលជាកំរិតបទដ្ឋានជំនួយ ហើយបានព្រមព្រៀងដោយរដ្ឋាភិបាលកម្ពុជា និង **"ក្រុមពិគ្រោះយោបល់"** របស់ម្ចាស់ជំនួយនៅខែធ្នូ ឆ្នាំ២០០៤កន្លងមកក្តី ក៏ម្ចាស់ជំនួយបានបង្កើនទឹកប្រាក់ជំនួយ

សំរាប់រដ្ឋាភិបាលដល់កំរិតខ្ពស់បំផុត ។ ចំពោះម្ចាស់ជំនួយ អ្នកការទូត និងសមាជិកដទៃទៀតនៃសហគមន៍អន្តរជាតិ ការគិតសារជាថ្មីនូវឥរិយាបថចំពោះប្រទេសកម្ពុជា គឺមានការយឺតយ៉ាវខ្លាំង ហើយត្រូវដោះស្រាយបញ្ហាជាមូលដ្ឋាន ដែលរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវការប្តេជ្ញាពិតប្រាកដតិចតួចដើម្បីធ្វើការកែទម្រង់ ។ ពួកគេគួរតែទទួលស្គាល់ថា ការរំលោភសិទ្ធិមនុស្សជាប្រព័ន្ធដែលកំពុងកើតមានឡើង នេះមានន័យថា រយៈពេលបច្ចុប្បន្ននៃភាពស្ងប់ស្ងាត់ខាងសង្គម និងនយោបាយរបស់កម្ពុជា គឺពុំមែនជាការធានានៃស្ថិរភាពយូរអង្វែងប្រកបដោយអត្ថន័យជាក់លាក់ឡើយ ។

របាយការណ៍សង្ខេបនេះ មានគោលបំណងបង្ហាញនូវបញ្ហាសិទ្ធិមនុស្សបន្ទាន់បំផុតរបស់កម្ពុជាជាច្រើនដែលកើតមាននៅក្នុងឆ្នាំ ២០០៦ ។ វាមានគោលបំណងលើកទឹកចិត្តអោយមានការវាយតម្លៃកាន់តែស៊ីជំរៅចំពោះស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងជំរុញអោយមានការពិភាក្សាគ្នា ។ របាយការណ៍នេះ មិនមែនជាគំរូល្អិតល្អន់នៃការរំលោភសិទ្ធិមនុស្សទេ ប៉ុន្តែ មានគោលបំណងផ្តល់នូវការវិភាគលើបញ្ហា និងព្រឹត្តិការណ៍សំខាន់ៗ ។

របាយការណ៍នេះ ក៏ចោទសួរសំណួរពិបាកៗមួយចំនួនផងដែរ : តើមានស្ថិរភាពពិតប្រាកដនៅក្នុងប្រទេសកម្ពុជា ដែរឬទេ ? តើកម្ពុជា ពិតជាមានប្រជាធិបតេយ្យពិតប្រាកដ ដែលបំរើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋខ្លួនឬទេ ? តើសហគមន៍អន្តរជាតិ មានតួនាទីអ្វីនៅក្នុងអនាគតរបស់ប្រទេសកម្ពុជា ?

# ដីធ្លី

ការកើនឡើងយ៉ាងខ្លាំងនូវជំលោះទាក់ទងនឹងបញ្ហាដីធ្លី គឺជានិន្នាការមួយក្នុងចំណោមនិន្នាការដ៏គួរអោយព្រួយបារម្ភបំផុត ដែលលេចឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយបង្កជាផលវិបាកដ៏រីករាលដាលចំពោះសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ។ ការចាប់យកដីធ្លីដោយខុសច្បាប់ ត្រូវបានអង្គការសហប្រជាជាតិពិពណ៌នាថាជា **"ភាពរីករាល"**[១] ដែលបង្កឡើងដោយអ្នកមានអំណាច និងអ្នកមានប្រាក់រឹបយកដីធ្លីពីប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងភាពក្រីក្រស្រាប់ទៅហើយ ហើយបញ្ហានេះកំពុងតែក្លាយជាផ្នែកមួយ ដែលកាន់តែរីកធំឡើងៗនៃការងាររបស់លីកាដូ (LICADHO) ។ ការពាក់ព័ន្ធរបស់ស្ថាប័នរដ្ឋ មន្ត្រី ទាហាន នគរបាល និងអ្នកជំនួញដែលមានទ្រព្យស្តុកស្តម្ភនៅក្នុងអំពើប្រឆាំង នឹងសហគមន៍ ឬពលរដ្ឋក្រីក្រ ធ្វើអោយការចាប់យកដីធ្លីក្លាយជាបញ្ហាមួយដែលរដ្ឋាភិបាលកម្ពុជាត្រូវតែទទួលខុសត្រូវ និងជាបញ្ហាមួយដែលសហគមន៍អន្តរជាតិត្រូវតែដោះស្រាយ ។ ការខកខានមិនបានដោះស្រាយបញ្ហានេះនឹងនាំអោយមានការអស់សង្ឃឹម ហើយនឹងបង្កើតក្រុមប្រជាពលរដ្ឋថ្នាក់ក្រោមក្រីក្របំផុត ដែលកាន់តែរីកធំឡើងៗ និងអាចបង្កគ្រោះថ្នាក់ ដោយពួកគេគ្មានអ្វីដែលត្រូវបាត់បង់ទៀតទេ ដែលនេះជាកត្តាបង្កើតអោយមានអស្ថិរភាព ។



ស្ត្រីព្នង ដែលរងគ្រោះដោយសារ ការរឹបអូសដីធ្លី នៅខេត្តមណ្ឌលគិរី ។

ស្ថិតិមានការកើនឡើងគួរអោយភ្ញាក់ផ្អើល ។ នៅក្នុងឆ្នាំ២០០៣ អង្គការលីកាដូ បានចូលរួម នៅក្នុងការអង្កេតតាមដានករណីចាប់យកដីធ្លី ចំនួន ២៥ករណី ប៉ុន្តែនៅក្នុងឆ្នាំបន្ទាប់មក ចំនួននេះបានកើនឡើងដល់ទៅ ១១២ ករណី ។ នៅក្នុងឆ្នាំ២០០៥ ចំនួននេះនៅតែកើនឡើងជាលំដាប់ ដោយអង្គការលីកាដូ បានរាយការណ៍អំពីករណីចាប់យកដីធ្លីចំនួន ១២៦ ករណី ដែលបានប៉ះពាល់ដល់គ្រួសារចំនួន ៩.៨៣២ គ្រួសារ ។

ដោយគិតថាគ្រួសារកម្ពុជាដែលមានសមាជិកមធ្យមច្រើនជាង ៥នាក់មានន័យថាក្នុងឆ្នាំ២០០៥ ពលរដ្ឋចំនួនប្រមាណ ៤៥.០០០នាក់ ត្រូវបានរងគ្រោះ ដោយសារករណីថ្មីៗនៃការចាប់យកដីធ្លីដោយខុសច្បាប់ ។ គួរកត់សំគាល់ផងដែរថា លីកាដូ ធ្វើការងារតែនៅក្នុងខេត្តចំនួន ១២ ក្នុងចំណោមខេត្ត-ក្រុងទាំង ២៤ របស់ប្រទេសកម្ពុជា ហេតុដូច្នេះ តួលេខសរុបអាចនឹងកើនខ្ពស់ជាងនេះច្រើនថែមទៀត ។ ការដែលមានជំលោះដីធ្លីភាគច្រើនអូសបន្លាយពេលជាច្រើនឆ្នាំ បានធ្វើអោយផលប៉ះពាល់កាន់តែកើនឡើងថែមទៀត ដែលបណ្តាលអោយចំនួន "ខ្មោចរស់" (ជនពនេចរ) ឬភាសាខ្មែរសាមញ្ញ ហៅថាអ្នកគ្មានដីធ្លីកាន់តែកើនឡើង ។

---

[១] លោក មីលូន កុដ្ឋារី តំណាងពិសេសរបស់អង្គកាសហប្រជាជាតិ ទទួលបន្ទុកផ្នែកទីលំនៅគ្រប់គ្រាន់ ខែកញ្ញា ឆ្នាំ២០០៥ http://news.bbc.co.uk/1/hi/world/asiapacific/4207138.stm

គោលនយោបាយម៉ៅនិយមជ្រុលរបស់របបខ្មែរក្រហម បានលុបចោលនូវកម្មសិទ្ធិដីធ្លីទាំងអស់នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ហើយចាប់តាំងពីពេលនោះមក ប្រទេសកម្ពុជាបានព្យាយាមប្រឹងប្រែង ដើម្បីបែងចែកដីធ្លីសារឡើងវិញ ដល់ប្រជាពលរដ្ឋរបស់ខ្លួន ។ ប៉ុន្តែជាអកុសល ស្ថាប័ន និងប្រព័ន្ធដែលបង្កើតឡើង ដើម្បីដោះស្រាយបញ្ហានេះភាគច្រើនទទួលបរាជ័យ ។ គណៈកម្មការសុរិយោដី ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០២ ជាយន្តការដោះស្រាយជំលោះ ដើម្បីកំណត់កម្មសិទ្ធិដីធ្លី ត្រូវបានរារាំងដោយការិយាធិបតេយ្យ (របៀបចាត់ការការងាររាជការ) និងអំពើពុករលួយ ។ ការបង្កើតអាជ្ញាធរជាតិសំរាប់ការដោះស្រាយវិវាទដីធ្លី (NALDR) កាលពីពេលថ្មីៗកន្លងមកនេះ ទំនងជាធ្វើអោយស្ថាប័នរដ្ឋាភិបាលផ្សេងទៀត ដែលមានស្រាប់ចុះខ្សោយ និងធ្វើអោយស្ថានការណ៍កាន់តែមានច្រើនថែមទៀត។ ជាក់ស្តែងច្បាប់ភូមិបាលរបស់ប្រទេសកម្ពុជា (និងអនុក្រឹត្យដែលពាក់ព័ន្ធមួយចំនួនទៀត) ជារឿយៗ ត្រូវបានបកស្រាយដោយមន្ត្រីពុករលួយ ឬមិនគោរពទាំងស្រុងតែម្តង ។

និយាយជាទូទៅជំលោះដីធ្លី ចាប់ផ្តើមឡើងជាមួយនឹងរូបភាពធំៗពីរ ការផ្តល់សម្បទានដីសេដ្ឋកិច្ចដល់ក្រុមហ៊ុនដាំចំការ ឬការបែងចែកដីអោយឯកជន ។ គិតជាសរុបផ្ទៃដី ២,៧លានហិកតា ឬ១៥% នៃផ្ទៃដីទាំងអស់របស់ប្រទេសកម្ពុជា ត្រូវបានបែងចែកសំរាប់សម្បទានដីធ្លី[២] ។ នៅក្នុងតំបន់សម្បទានជាច្រើនក្រុមហ៊ុនពុំមានសកម្មភាពអ្វីឡើយនាពេលបច្ចុប្បន្ន ប៉ុន្តែការជួលក្នុងរយៈពេលវែង (ជាធម្មតា ៧០ឆ្នាំ) មានន័យថា ពួកគេអាចត្រឡប់ទៅចាប់ផ្តើការរុករានឆ្ការនៅពេលណាមួយក៏បាន ។

ផលប៉ះពាល់អវិជ្ជមាននៃសម្បទានដីធ្លី ត្រូវបានចុះជាឯកសារត្រឹមត្រូវ កាលពីពេលថ្មីៗបំផុតនេះដោយអតីតតំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្សប្រចាំកម្ពុជា គឺលោក ភីធើ ឡឺប្រិច (Peter Leuprecht) ។ ដោយមិនអើពើក្នុងការគោរពច្បាប់ភូមិបាល ដែលកំណត់ទំហំដីសម្បទាន ត្រឹម ១០.០០០ហិកតា រដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ដីសម្បទានដែលមានទំហំដល់ទៅ ១៧៦.០០០ហិកតា នៅក្នុងកិច្ចព្រមព្រៀងដែលត្រូវបានគេរក្សាទុកជាការសំងាត់ បើទោះជាមានការអំពាវនាវជាអន្តរជាតិសុំអោយមានតម្លាភាពយ៉ាងណាក៏ដោយ[៣] ។ ផលប្រយោជន៏សំរាប់រដ្ឋ (ការបង់ពន្ធ) ត្រូវបានបិទបាំងដោយទង្វើសំងាត់បែបនេះ ។ កាតព្វកិច្ចផ្លូវច្បាប់របស់ក្រុមហ៊ុន ក្នុងការអនុវត្តការវាយតំលៃផលប៉ះពាល់ផ្នែកបរិស្ថានភាគច្រើនត្រូវបានគេមិនអើពើគោរពតាមទេ ចំណែកការវាយតំលៃផលប៉ះពាល់ផ្នែកសង្គម និងការពិគ្រោះយោបល់ជាមួយសហគមន៏ ក៏មិនដែលត្រូវបានគេតំរូវអោយធ្វើផងដែរ[៤] ។ ជាលទ្ធផលនៅពេលដែល

[២] តំណាងពិសេសរបស់អគ្គលេខាធិការ អ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា *សម្បទានដីធ្លីសំរាប់គោលបំណងសេដ្ឋកិច្ច នៅកម្ពុជា : ទស្សនវិស័យសិទ្ធិមនុស្ស* ខែវិច្ឆិកា ឆ្នាំ២០០៤ ។ អាចរកមើលនៅលើ : http://cambodia.ohchr.org/report_subject.aspx ។

[៣] ក្រុមហ៊ុនភាពីម៉ិច ចុះហត្ថលេខាលើកិច្ចសន្យា នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០០ សំរាប់ដីសម្បទានទំហំ ១៧៦.០៦៥ហិកតា នៅខេត្តកំពង់ឆ្នាំង និងកិច្ចសន្យាមួយទៀតសំរាប់ ដីសម្បទានទំហំ ១៣៨.៩៦៣ហិកតា នៅខេត្តពោធិ៍សាត់ នៅថ្ងៃដដែល បើយោងតាមរបាយការណ៍ស្តីពីសម្បទានដីធ្លីរបស់តំណាងពិសេសរបស់អ.ស.ប.។ របាយការណ៏ ក៏បានកត់សំគាល់ផងដែរថាមានប្រជាពលរដ្ឋជាង ១០០.០០០នាក់ ដែលរស់នៅលើតំបន់ដីសម្បទាននេះ ។ សូចនាករត្រួតពិនិត្យអាទិភាព ឆ្នាំ២០០៤ របស់ក្រុមពិគ្រោះយោបល់បានរាប់បញ្ចូលនូវ "ការបញ្ចេញអោយដឹងជាសាធារណៈភ្លាមៗនូវកិច្ចសន្យាសាធារណៈ និងការអនុវត្តតាម (កំរៃសួយសារ និងខចែងសំខាន់ៗដទៃទៀត) នៃកិច្ចសន្យា ដែលគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច..." អាចរកមើលនៅលើ : http://web.worldbank.org/WEBSITE/EXTERNAL/COUNTRIES/ EASTASIAPACIFICEXT / CAMBODIAEXTN/0,,contentMDK:20291611~menuPK:293876~pagePK:64027986~piPK:64027986~theSitePK:293856,00.html ។

[៤] អនុក្រឹត្យមួយដែលចេញនៅពេលក្រោយបានកំណត់ការវាយតំលៃផលប៉ះពាល់សង្គមជាលក្ខខណ្ឌតំរូវដោយច្បាប់ ប៉ុន្តែអនុក្រឹត្យនេះមិនទាន់ចូលជាធរមានទេ នៅពេលដែលដីសម្បទានជាច្រើនបំផុតត្រូវបានផ្តល់ ។

ក្រុមហ៊ុនចាប់ផ្ដើមឆ្ការរានដី សំរាប់ការធ្វើចំការ (ជាទូទៅ ដូចជាដើមប្រេងខ្យល់, កៅស៊ូ, ម៉ៃសាក់, ដូងប្រេង និងដូង) ពួកគេប្រឈមនឹងការប្រឆាំងតវ៉ាពីពលរដ្ឋក្នុងមូលដ្ឋាន ដែលជារឿយៗ បានរស់នៅលើដីនោះរយៈពេលច្រើនជាង ៥ឆ្នាំ ដូច្នេះហើយ មានសិទ្ធិទាមទារដីនោះតាមច្បាប់កម្ពុជាស្ដីពីកម្មសិទ្ធិតាមរយៈការកាន់កាប់ ។ នៅក្នុងខេត្តពោធិ៍សាត់ ក្រុមហ៊ុនភាពីម៉ិច (ដែលគ្រប់គ្រងដីសម្បទាន ដែលឧបត្ថម្ភមូលនិធិដោយប្រាក់កម្ចីរបស់រដ្ឋាភិបាលចិន) បានបន្តឡើងវិញនូវការកាប់ឆ្ការរានដីសម្បទានរបស់ខ្លួន ដែលមានទំហំ ១៣៨.៩៦៣ ហិកតា នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៥[៥] នៅក្រោយពេលដែលការតវ៉ាមុនៗ បានធ្វើអោយក្រុមហ៊ុននេះបញ្ឈប់ការឆ្ការរានដីនោះមក ។

**"ខ្ញុំសូមព្រមានថា ប្រសិនបើ នៅតែបន្ត ចាប់យកដីធ្លីទៀត នឹងមានបដិវត្តន៍ កសិករ...លួមឈប់ហើយ មុនពេលប្រជាពលរដ្ឋអស់ការអត់ធ្មត់"** ។ នេះជាប្រសាសន៍ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីខែ តុលា ឆ្នាំ២០០៥ ។

សមាជិកសហគមន៍ដែលរស់នៅពឹងផ្អែកលើការធ្វើស្រែចំការនិងប្រមូលផលព្រៃឈើ បានធ្វើការតវ៉ាដោយសន្តិវិធីសារជាថ្មីម្ដងទៀត ប្រឆាំងនឹងការរឹបអូសយកដីធ្លីរបស់ពួកគាត់ ។ នៅយប់ថ្ងៃទី១៣ ខែវិច្ឆិកា គ្រាប់បែកដៃមួយគ្រាប់ត្រូវបានគប់ទៅលើជំរំបណ្ដោះអាសន្នរបស់សហគមន៍ដែលធ្វើការតវ៉ានោះដោយបង្កអោយមនុស្ស ៨ នាក់រងរបួស ។ នគរបាលមិនបានរកឃើញជនសង្ស័យទាក់ទង នឹងការគប់គ្រាប់បែកនេះឡើយ ។ ការកាប់ឆ្ការរានយកដីបានបញ្ឈប់ (គ្រឿងចក្រត្រូវបានគេរាយការណ៍ថា បានត្រូវគេយកទៅដាក់នៅក្នុងដីសម្បទានរបស់ក្រុមហ៊ុន Wuzhishan នៅខេត្តមណ្ឌលគិរី) ប៉ុន្តែសហគមន៍នៅតែមានការព្រួយបារម្ភថា ក្រុមហ៊ុនអាចនឹងវិលត្រឡប់មកវិញនៅពេលណាមួយ ។

ទិដ្ឋភាពមួយក្នុងចំណោមទិដ្ឋភាព ដែលគួរអោយព្រួយបារម្ភបំផុតជាច្រើននៃសម្បទានដីធ្លីទាំងនេះ គឺជាការបញ្ជូនសារមួយថា រដ្ឋាភិបាលបានត្រៀមខ្លួនដាក់តម្កល់កិច្ចការជំនួញដែលគួរអោយមន្ទិលសង្ស័យខ្ពស់ជាងសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ។ ការឃុបឃិតគ្នារវាងនគរបាល និងមន្ត្រីរដ្ឋអំណាចមូលដ្ឋានជួយគាំទ្របន្ថែមដល់គោលនយោបាយនេះ ។

បុគ្គលមានអំណាច ក៏កំពុងធ្វើការទាមទារកម្មសិទ្ធិលើដីធ្លីដែលគួរអោយមន្ទិលសង្ស័យផងដែរ ហើយជួនកាលប្រើប្រាស់កំលាំង ដើម្បីបណ្ដេញប្រជាពលរដ្ឋចេញថែមទៀតផង ។ អ្នកដែលមានលុយទិញកម្មសិទ្ធិដីធ្លីដែលក្លែងបន្លំ ឬសូកប៉ាន់មន្ត្រីមូលដ្ឋាន ដើម្បីអោយផ្ដល់ការយល់ព្រមដល់ការទាមទារកម្មសិទ្ធិលើដីធ្លីរបស់ខ្លួន ហើយបន្ទាប់មកអះអាងថាអ្នកដែលរស់នៅលើដីនោះ គឺជាអ្នកតាំងលំនៅអនាធិបតេយ្យខុសច្បាប់ ។ ឧទាហរណ៍ ដ៏គួរអោយតក់ស្លុតបំផុតនៃការចាប់យកដីធ្លីប្រភេទនេះបានផ្ទុះឡើង នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ នៅភូមិក្បាលស្ពានជាប់ព្រំដែនថៃក្នុងខេត្តបន្ទាយមានជ័យ ។ ក្នុងអំឡុងពេលនៃការប្រឈមមុខដាក់គ្នាក្នុងរឿងជំលោះដីធ្លីនេះ នគរបាលនិងទាហានបានបាញ់កាំភ្លើងទៅលើហ្វូងអ្នកតវ៉ា ធ្វើអោយស្លាប់មនុស្សចំនួន ៥នាក់

---

[៥] តំណាងពិសេសរបស់អគ្គលេខាធិការ អ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា *សម្បទានដីធ្លីសំរាប់គោលបំណងសេដ្ឋកិច្ច នៅកម្ពុជា : ទស្សនវិស័យសិទ្ធិមនុស្ស* ខែវិច្ឆិកា ឆ្នាំ២០០៤ ។ អាចរកមើលនៅលើ : http://cambodia.ohchr.org/report_subject.aspx ។

និងរបួសចំនួន ៤០នាក់ផ្សេងទៀត[៦] ។ ដីមួយក្បាលនៅក្បែរព្រំដែនថៃ ដែលពីមុនគ្មាននរណាចាប់អារម្មណ៍អស់រយៈពេលជាច្រើនឆ្នាំមកហើយនោះ ឥឡូវនឹងបានកំពុងក្លាយជាដីដ៏មានតំលៃ ដោយសារតែវាមានទីតាំងនៅក្បែរកាស៊ីណូ ។

មេភូមិដែលបានទាមទារកម្មសិទ្ធិលើដីនោះ គឺជាមនុស្សដែលសហគមន៍មូលដ្ឋានពុំដែលស្គាល់ឡើយ ប៉ុន្តែ បានប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ក្នុងការទទួលបានដីកាពីតុលាការខេត្ត ដើម្បីបណ្តេញប្រជាពលរដ្ឋចេញពី ដីនោះ និងប្រើប្រាស់កំលាំងនគរបាលនិងកងរាជអាវុធហត្ថ ១២៨នាក់ ដើម្បីអនុវត្តការបណ្តេញចេញនោះ ។ ការធ្វើអន្តរាគមន៍ដ៏ខ្លាំងក្លាពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក (NGOs) ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសហគមន៍អន្តរជាតិបានជំរុញអោយមានការចាប់ខ្លួន ប៉ុន្តែក្រោយមក ការចោទប្រកាន់ត្រូវបានលើកលែង ហើយជនសង្ស័យក៏ត្រូវបានដោះលែងអោយរួចខ្លួនវិញ ។ ទន្ទឹមនឹងពេលដែលព្រឹត្តិការណ៍នៅភូមិក្បាលស្ពាន គឺជាករណីដ៏ធ្ងន់ធ្ងរបំផុតមួយ ការប្រឈមមុខប្រហាក់ប្រហែលគ្នានេះកំពុងក្លាយជាព្រឹត្តិការណ៍ ដែលកើតឡើងកាន់តែញឹកញាប់ឡើងៗ ។

ភាគច្រើននៃមេគំនិតដែលចាប់យកដីធ្លីដែលត្រូវបានរាយការណ៍ដោយលីកាដូ គឺទាហាន នគរបាល ឬមន្ត្រីរដ្ឋអំណាចមូលដ្ឋាន ។ ជារឿយៗ ការគំរាមកំហែង ការបំភិតបំភ័យ និងអំពើហិង្សាត្រូវបានគេប្រើប្រាស់ដើម្បីអនុវត្តការបណ្តេញពលរដ្ឋចេញ ហើយសំណងសមរម្យ គឺកំរនឹងត្រូវបានគេពិចារណាណាស់ ។ ជារឿយៗ រដ្ឋាភិបាលខកខានមិនទទួលខុសត្រូវដោយអនុញ្ញាតអោយមន្ត្រីថ្នាក់ខេត្ត និងថ្នាក់ស្រុក នគរបាល និងទាហានរឹបអូសយកដីធ្លីប្រើអំពើហិង្សា ហើយទទួលបានអភ័យឯកសិទ្ធិពីការផ្តន្ទាទោស (ការរួចផុតពីទោសពៃរ៍) ។

រដ្ឋាភិបាលក៏បានរារាំងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដែលធ្វើការងារពាក់ព័ន្ធរឿងដីធ្លីត្រូវប្រឈមមុខនិងការគំរាមកំហែង និងឧបស័គ្គផងដែរ ។ នៅឆ្នាំ ២០០៥ អង្គការឃ្លាំមើលព្រៃឈើឯករាជ្យឈ្មោះ Global Witness ដែលមានមូលដ្ឋាននៅទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស ត្រូវបិទការិយាល័យរបស់ខ្លួននៅក្នុងទីក្រុងភ្នំពេញបន្ទាប់ពីការគំរាមកំហែងទៅលើបុគ្គលិកខ្មែរបានកើនឡើងយ៉ាងខ្លាំង ។ ការបំភិតបំភ័យរួមមានការវាយប្រហារលើរាងកាយបុគ្គលិកខ្មែរម្នាក់នៅខាងក្រៅការិយាល័យរបស់ Global Witness ការបដិសេធន៏មិនអោយបុគ្គលិកជនជាតិបរទេសចូលប្រទេសកម្ពុជា **"ការដាក់ក្នុងបញ្ជីខ្មៅ"** នូវបុគ្គលិកដទៃទៀតជាច្រើននាក់ និងការរឹបអូសដោយអាជ្ញាធរគយកម្ពុជានូវរបាយការណ៍ចំរូងចំរាស់ ដែលបញ្ចេញឈ្មោះបុគ្គលិករដ្ឋដែលពាក់ព័ន្ធ នឹងការកាប់បំផ្លាញព្រៃឈើ ។ នៅក្នុងខែកញ្ញា ឆ្នាំ២០០៤ នាយករដ្ឋមន្ត្រីខ្លួនឯងបានគូសបញ្ជាក់ថា អង្គការ Global Witness ត្រូវ "**បញ្ចប់**" នៅប្រទេសកម្ពុជា ។[៧] ប៉ុន្តែ ៧ខែ ក្រោយមកនាយករដ្ឋមន្ត្រីបានត្អូញត្អែរថា ម្ចាស់ជំនួយសុំ

[៦] ក្រុមហ៊ុនសម្បទានមួយទៀត ដែលគាំទ្រដោយរដ្ឋាភិបាលចិន ឈ្មោះ Wuzhishan បានផ្តល់សមត្ថភាពបច្ចេកទេស ដល់ការឆ្ការរានដីរបស់ក្រុមហ៊ុនភាពីម៉ិច បើយោងតាម របាយការណ៍ អ.ស.ប. ស្តីពីដីសម្បទាន ឆ្នាំ២០០៤ ។

[៧] គណៈកម្មាធិការប្រព្រឹត្តិកម្មសិទ្ធិមនុស្ស កម្ពុជា (CHRAC) *តំលៃដ៏ខ្ពស់នៃដីធ្លី : ការបណ្តេញអ្នកភូមិក្បាលស្ពានដែលបណ្តាលអោយស្លាប់មនុស្ស* ខែសីហា ឆ្នាំ២០០៥ ។

អោយលោកបញ្ឈប់ការកាប់ឈើដោយខុសច្បាប់ ដោយមិនបានផ្តល់មូលនិធិសំរាប់ការត្រួតពិនិត្យព្រៃឈើដោយឯករាជ្យ ដូចតួនាទីដែល Global Witness ធ្លាប់បានទទួលអនុវត្តពីមុនមក[៨] ឡើយ ។

ការចាប់យកដីធ្លី គឺជាការរំលោភសិទ្ធិមនុស្ស-វារំលោភលើសិទ្ធិក្នុងការទទួលបាន "ជីវភាពរស់នៅគ្រប់គ្រាន់ ក្នុងនោះរាប់ទាំងសិទ្ធិក្នុងការមានទីលំនៅសមរម្យ និងការកែលំអជីវភាពរស់នៅជាបន្តបន្ទាប់" ដូចដែលត្រូវបានកំណត់ដោយកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន[៩] ។

ការរឹបអូសដីធ្លីដោយខុសច្បាប់ ក៏បង្កើតភាពងាយទទួលរងគ្រោះរបស់ប្រជាពលរដ្ឋពីការរំលោភសិទ្ធិផ្សេងៗទៀតផងដែរ ។ ពលរដ្ឋខ្មែរប្រមាណ ៣ភាគ៤ ពឹងផ្អែកលើដីធ្លីសំរាប់ការប្រកបរបរចិញ្ចឹមជីវិត[១០] ហើយការរឹបអូសដីធ្លីពីគ្រួសារប្រជាពលរដ្ឋ ធ្វើអោយពួកគេបាត់បង់នូវប្រភពស្បៀងអាហារ និងប្រភពរកប្រាក់ចំណូលដែលនាំទៅរកភាពក្រីក្រ ។ ក្រៅពីការធ្វើស្រែចំការ លទ្ធភាពក្នុងការប្រើប្រាស់ដីធ្លី ក៏នាំមកនូវលទ្ធភាពក្នុងការប្រមូលផលព្រៃឈើផ្សេងៗទៀតសំរាប់ការលក់ដូរផងដែរ (ឧទាហរណ៍: ជ័រឈើ ផ្តៅ) ឬសំរាប់ការទទួលអាហារ (ដូចជា: ផ្លែឈើ បន្លែព្រៃ) ។ នៅក្នុងករណីជាច្រើន ភាពគ្មានទីលំនៅ និងកង្វះម្ហូបអាហារ គឺជាលទ្ធផលកើតមានក្រោយពេលការរឹបអូសដីធ្លី ហើយប្រជាពលរដ្ឋកាន់តែងាយទទួលរងគ្រោះខ្លាំងឡើងពីការជួញដូរមនុស្ស និងអំពើឧក្រិដ្ឋ ។

ជារឿយៗ ការផ្លាស់ទីមកទីក្រុង ជាចំណុចចាប់ផ្តើមនៃការធ្លាក់ចូលទៅក្នុងភាពក្រីក្រកាន់តែធ្ងន់ធ្ងរដែលមិនអាចបកក្រោយបាន។ កំណើននៃចំនួនប្រជាពលរដ្ឋក្រីក្រដែលគ្មានអ្វីសេសសល់ដែលត្រូវបាត់បង់ ត្រូវបានកត់សំគាល់ដោយតំណាងពិសេសរបស់អ.ស.ប ទទួលបន្ទុកផ្នែកទីលំនៅសមរម្យ លោក **មីលូន កុដ្ឋារី** ហើយត្រូវបានកត់សំគាល់ដោយនាយករដ្ឋមន្ត្រី ថាជាកត្តាបង្កអស្ថិរភាពក្នុងសង្គម ។ ប៉ុន្តែទោះបីជា មានការសន្យាប្រយុទ្ធប្រឆាំងនឹងការចាប់យកដីធ្លីក្តី លីកាដូ បានឃើញភស្តុតាងតិចតួចណាស់ នៃសកម្មភាពពិតប្រាកដក្នុងការបញ្ឈប់អ្នកមានប្រាក់ និងអ្នកមានអំណាចកុំអោយកេងប្រវ័ញ្ចអ្នកក្រ និងអ្នកងាយរងគ្រោះ ។

---

[៨] Pinn Sisovann and Lee Berthiaume, "នាយករដ្ឋមន្ត្រីរិះគន់ Global Witness, និយាយថា អង្គការនេះចប់ហើយ" *កាសែតឌឹខែមបូឌា ដេលី* ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៥ ។

[៩] Erik Wasson and Kay Kimsong, "នាយករដ្ឋមន្ត្រីនិយាយទៅកាន់ម្ចាស់ជំនួយ : ខ្ញុំតែម្នាក់ឯងអាចកែទំរង់រដ្ឋាភិបាលបាន" *កាសែតឌឹខែមបូឌា ដេលី* ថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០០៥ ។

[១០] មាត្រាទី ១១ "១. រដ្ឋជាភាគីនៃអនុសញ្ញានាពេលបច្ចុប្បន្ន ទទួលស្គាល់នូវសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបាននូវជីវភាពគ្រប់គ្រាន់សំរាប់ ខ្លួនឯង និងគ្រួសារក្នុងនោះរាប់បញ្ចូលទាំងការមានស្បៀងអាហារ សំលៀកបំពាក់ និងជំរកស្នាក់នៅគ្រប់គ្រាន់ និងសិទ្ធិក្នុងការទទួលបានការកែលំអជីវ ភាពរស់នៅជាបន្តបន្ទាប់ ។ រដ្ឋជាភាគីនឹងចាត់វិធានការសមស្រប ដើម្បីធានាការសំរេចបាននូវសិទ្ធិនេះ ដោយទទួលស្គាល់នូវសារសំខាន់ជាសារវន្ត នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ឈរលើមូលដ្ឋាននៃការព្រមព្រៀងដោយសេរី" (http://www.ohchr.org/english/law/cescr.htm) ។

## ករណីសិក្សា : ដីសម្បទានក្រុមហ៊ុន Wuzhishan នៅខេត្តមណ្ឌលគិរី

នៅក្នុងឆ្នាំ២០០៤ រដ្ឋាភិបាលកម្ពុជាបានយល់ព្រមផ្តល់ដីទំហំ ១៩៩.០០០ហិកតា នៅក្នុងខេត្តមណ្ឌលគិរី ទៅអោយក្រុមហ៊ុន Wuzhishan L.S. Group ដែលជាក្រុមហ៊ុនគ្រប់គ្រងដោយជនជាតិខ្មែរ-ចិន ដើម្បីធ្វើចំការដាំដើមស្រល់ ។ ដីសម្បទាននេះ មានទំហំធំជាងទំហំដែលអនុញ្ញាតដោយច្បាប់កម្ពុជា ប្រមាណ ២០ដង ។ រដ្ឋាភិបាលក៏បានអនុម័ត ផ្តល់ដីចំនួន១០.០០០ហិកតាភ្លាមៗ ផងដែរសំរាប់ការធ្វើពិសោធន៏ និងការដាំដុះដោយដីដែលនៅសល់ នឹងត្រូវផ្តល់អោយនៅពេលក្រោយបន្ទាប់ពីមានកិច្ចពិភាក្សាបន្ថែមទៀតជាមួយម្ចាស់ជំនួយរបស់ប្រទេសកម្ពុជា ។ ប៉ុន្តែ សេចក្តីលំអិត នៃកិច្ចព្រមព្រៀងនេះត្រូវបានគេរក្សាទុកជាការសំងាត់ ហើយពុំមានការវាយតំលៃផលប៉ះពាល់បរិស្ថាន ឬផលប៉ះពាល់សង្គមណាមួយ ដែលត្រូវបានគេអនុវត្តឡើយ ។

ដីសម្បទាននេះមានទីតាំងស្ថិតនៅក្នុងតំបន់ដែលមានសហគមន៏ជនជាតិភាគតិចព្នងរស់នៅ ហើយសកម្មភាពរបស់ក្រុមហ៊ុនសម្បទាននេះបានបង្កផលវិបាកដ៏រីករាលដាលដល់ពលរដ្ឋជនជាតិព្នងទាំងនេះ ។ កម្មកររបស់ក្រុមហ៊ុន Wuzhishan បានប្រមាថលើទីតាំងសក្ការបូជារបស់ជនជាតិភាគតិចក្នុងនោះរួមមាន ដីបញ្ចុះសព និងព្រៃសក្ការៈ ដោយលួចឬបំផ្លាញគ្រឿងដង្វាយដែលគេដាក់នៅកន្លែងបញ្ចុះសព ។ ដីដែលជនជាតិព្នងប្រើប្រាស់ ដើម្បីឃ្វាលសត្វពាហនៈ នៅក្នុងប្រព័ន្ធកសិកម្មឆ្លាស់ដំណាំតាមរដូវ ត្រូវបានបាត់បង់ ទៅជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ។

ផ្លែឈើ បន្លែ និងសត្វចិញ្ចឹមរបស់អ្នកភូមិ ត្រូវបានបុគ្គលិកកម្មកររបស់ក្រុមហ៊ុន Wuzhishan លួចយក ។ តំណាងរបស់ក្រុមហ៊ុនបានបាញ់សារធាតុគីមីសំលាប់រុក្ខជាតិ ហៅថា Glyphosate ដែលទីភ្នាក់ងារការពារបរិស្ថានអាមេរិកថាមានការជាប់ទាក់ទងនឹង ការធ្វើអោយប៉ះពាល់ដល់តំរងនោម និងសរីរាង្គបន្តពូជ ដោយធ្វើអោយជនជាតិព្នងគ្មានដីធ្លី ដែលអាចប្រើប្រាស់បាន និងអាចបង្កបញ្ហាប៉ះពាល់ដល់សុខភាព ។ នៅពេលដែលសហគមន៏បានប្តឹងតវ៉ាអំពីក្រុមហ៊ុននេះពួកគេត្រូវបានគំរាមនិងបំភិតបំភ័យដោយតំណាងរបស់ក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋាន ។

នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៥ អ្នកភូមិប្រមាណ ៦៥០នាក់ មកពីឃុំសែនមនោរម្យ និងឃុំដាក់ដាំ ខេត្តមណ្ឌលគិរី បាននាំគ្នាធ្វើការតវ៉ា ហើយត្រូវបានបំបែកដោយកំលាំងនគរបាលខេត្ត ៥០នាក់ ដែលបានបាញ់ទឹកលើហ្វូងអ្នកតវ៉ាបណ្តាល អោយស្ត្រីពីរនាក់សន្លប់បាត់ស្មារតី ។

នៅថ្ងៃបន្ទាប់ រដ្ឋាភិបាលកម្ពុជាបានចេញបញ្ជាអោយក្រុមហ៊ុន Wuzhishan ផ្អាកសកម្មភាពជាបណ្តោះអាសន្ន និងបានបញ្ជាអោយអាជ្ញាធរខេត្តមណ្ឌលគិរីធ្វើយ៉ាងណាធានាថា ដីរបស់អ្នកភូមិក្នុងមូលដ្ឋានមិនត្រូវបានដាក់បញ្ចូលនៅក្នុងតំបន់សម្បទាននោះ ។ ទោះបី ជាមានបញ្ជាពីរដ្ឋាភិបាលយ៉ាងនេះក៏ដោយ ក៏ក្រុមហ៊ុន Wuzhishan នៅតែបន្តដាំដើម ស្រល់ដដែល ហើយអាជ្ញាធរមូលដ្ឋានមិន បានចាត់វិធានការជាដុំកំភួនដើម្បីទប់ស្កាត់បញ្ហានេះឡើយ ។ ផ្ទុយទៅវិញកំលាំងនគរបាល និងមន្ត្រីរដ្ឋាភិបាលបានបង្កើនកិច្ចប្រឹងប្រែងរបស់ពួកគេ ដើម្បីព្យាយាមបញ្ឈប់អ្នកភូមិជនជាតិព្នងដែលធ្វើការតវ៉ា និងរាំងផ្លូវមិនអោយឡានរបស់ក្រុមហ៊ុនចូលក្នុងតំបន់ដីសម្បទាន ។

នៅថ្ងៃទី០៧ ខែកក្កដា អ្នកភូមិប្រមាណ ១.០០០នាក់ បានព្យាយាមធ្វើការតវ៉ាប្រឆាំងនឹងការមិនព្រមអនុវត្តបទបញ្ជារដ្ឋាភិបាល ក្នុងការផ្អាកសកម្មភាពរបស់ក្រុមហ៊ុន ។ បាតុករប្រមាណ ២០០នាក់ បានដើរក្បួនតវ៉ាដល់ទីរួមខេត្តសែនមនោរម្យនៃខេត្តមណ្ឌលគិរី ហើយបានជួបប្រជុំជាមួយតំណាងរដ្ឋាភិបាល ។ បាតុករផ្សេងទៀតត្រូវបានបង្ខំអោយត្រឡប់ក្រោយវិញដោយកំលាំងនគរបាល ។ ពីរថ្ងៃក្រោយមក ព្រះមហាក្សត្រព្រះបាទបរមនាថ នរោត្តម សីហមុនី បានយាងទៅធ្វើទស្សនកិច្ចនៅខេត្តមណ្ឌលគិរី ដើម្បីប្រារព្ធទិវាដាំដើមឈើ ដោយព្រះអង្គបានចូលរួមដាំដើមឈើ ។ នៅក្នុងព្រះរាជសុន្ទរកថារបស់ព្រះអង្គ

ព្រះមហាក្សត្របានបញ្ជាក់អំពីកង្វល់របស់សហគមន៍ម្ចាស់ស្រុក ដោយព្រះអង្គមានព្រះបន្ទូលបន្ថែមថា ព្រះអង្គ និងព្រះរាជវង្សានុវង្ស ចូលរួមរំលែកនូវទុក្ខសោករបស់ក្រុមប្រជាពលរដ្ឋដែលទទួលរងគ្រោះ ។

បញ្ហានៅតែបន្តកើតមាន នៅក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុន Wuzhishan ។ នៅក្នុងខែមីនា ឆ្នាំ២០០៦ អ្នកភូមិបានផ្តល់របាយការណ៍ជាច្រើនដល់អង្គការលើកលែងទោសអន្តរជាតិ (Amnesty International) ដោយលើកឡើងពីការលួចសត្វពាហនៈ និងដំណាំនៅក្នុងឆ្នាំកន្លងទៅ ដោយអាជ្ញាធរនគរបាលពុំមានចាត់វិធានការប្រកបដោយប្រសិទ្ធភាពអ្វីឡើយ ។ អភិបាលរងខេត្តមណ្ឌលគិរី បានមានប្រសាសន៍ថា លោកគិតថា "បញ្ហា" ថ្មីៗ នឹងកើតមានឡើងទៀត នៅពេលដែលក្រុមហ៊ុនបន្តការដាំដុះនៅក្នុងរដូវវស្សាពាក់កណ្តាលឆ្នាំ២០០៦ ។

# សេរីភាពប្រជាធិបតេយ្យថមថយ

ឆ្នាំ២០០៥ និងដើមឆ្នាំ២០០៦ ត្រូវបានកត់សំគាល់ដោយសារការរឹតត្បិតយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំដោយសន្តិវិធី ។ ការរឹតត្បិតទាំងនេះត្រូវបានឆ្លុះបញ្ចាំងអោយឃើញតាមរយៈកិច្ចប្រឹងប្រែងដែលកាន់តែកើនឡើងរបស់ស្ថាប័ន នីតិប្រតិបត្តិក្នុងការបំបិទមាត់អ្នកជំទាស់តវ៉ា ។

នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៥ រដ្ឋសភាបានបោះឆ្នោតដកអភ័យឯកសិទ្ធិសភាពី អ្នកតំណាងរាស្ត្របីរូបមកពីគណបក្សសមរង្ស៊ី (SRP) គឺឯកឧត្តម សម រង្ស៊ី ,ឯកឧត្តម ជា ប៉ូច និងឯកឧត្តម ជាម ច័ន្ទនី នៅក្នុងកិច្ចប្រជុំបិទទ្វារមួយ ។ ទង្វើនេះបានបើកផ្លូវអោយអ្នកទាំងបីត្រូវគេនាំទៅកាត់ទោសពីបទឧក្រិដ្ឋ[១១] និងត្រូវបានចាត់ទុកដោយមជ្ឈដ្ឋានភាគច្រើន ក្នុងនោះរួមទាំងលីកាដូ ថាជាការវាយប្រហារផ្នែកនយោបាយទៅលើគណបក្សសំលេងជំទាស់ ។ ទំលាប់នៃការដកអភ័យឯកសិទ្ធិសភាពីអ្នកតំណាងរាស្ត្រ ដែលនិយាយរិះគន់នាយករដ្ឋមន្ត្រីធ្លាប់កើតមានពីមុនមកនៅក្នុងប្រវត្តិសាស្ត្រថ្មីៗចុងក្រោយនេះ ។

**"ការចាប់ខ្លួន ឬការគំរាមចាប់ខ្លួនតំណាងរាស្ត្របក្សប្រឆាំង និងសកម្មជនការពារសិទ្ធិមនុស្ស នាំអោយគេជឿថាមាននិន្នាការមួយឆ្ពោះទៅរករដ្ឋាភិបាលផ្តាច់ការ" ។**

សហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ ខែកុម្ភៈ ឆ្នាំ ២០០៦ ។

នៅក្នុងឆ្នាំ១៩៩៥ សម្តេចនរោត្តម សិរីវុឌ្ឍ អតីតរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមកពីគណបក្ស ហ្វ៊ុនស៊ិនប៉ិច (ឬរណសិរ្សរួបរួមជាតិសំរាប់កម្ពុជាឯករាជ្យ អព្យាក្រឹត្យ សន្តិភាព និងសហប្រតិបត្តិការ) ត្រូវបានដកហូតអភ័យឯកសិទ្ធិសភា និងចាប់ខ្លួនក្រោយពីត្រូវបានចោទប្រកាន់ពីបទពាក់ព័ន្ធ នឹងការបង្កើតកងកំលាំងប្រដាប់អាវុធប៉ុនប៉ងផ្តួលរំលំរដ្ឋាភិបាល និងភេរវកម្ម ។ ការចោទប្រកាន់នេះ ជាការមិនគួរអោយជឿ[១២] ហើយអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) បានចាត់ទុកសម្តេចនរោត្តម សិរីវុឌ្ឍថាជា "អ្នកទោសនយោបាយ"[១៣] ។ ជាការគួរអោយហួសចិត្ត គឺព្រះអង្គម្ចាស់សិរីវុឌ្ឍ បានដើរតួក្នុងនាមតំណាងអោយគណបក្សហ៊្វុនស៊ិនប៉ិច-ដែលក្រោយមកបានដាក់ពាក្យបណ្តឹងពីបទបរិហារកេរ្តិ៍ប្រឆាំងនឹងតំណាងរាស្ត្រ ជា ប៉ូច និង សម រង្ស៊ី[១៤] ។

មេរៀនពីឧប្បត្តិហេតុទាំងនេះ គឺថាសូម្បី តែស្ថាប័នដែលជាមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ រដ្ឋសភាគឺជាវេទិកាសំខាន់សំរាប់ការពិភាក្សាច្បាប់ថ្មីៗ ក៏ងាយនឹងទទួលរងការជ្រៀតជ្រែកពីស្ថាប័ននីតិប្រតិបត្តិដែរ ។ អភ័យឯកសិទ្ធិសភាគឺសំរាប់អោយអ្នកតាក់តែងច្បាប់អាចធ្វើការពិភាក្សាអំពីបញ្ហាចំរូងចំរាស់ ដើម្បីផលប្រយោជន៍

---

[១១] ស្ថិតិជំរឿនប្រជាពលរដ្ឋទូទៅ ឆ្នាំ១៩៩៨ បានរកឃើញថា ប្រជាពលរដ្ឋខ្មែរ ៧៦.៥% ធ្វើការងារនៅក្នុងផ្នែកកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

[១២] សម រង្ស៊ី និងជា ប៉ូច មានការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ នៅរង់ចាំការបើកសវនាការ ហើយ ជាម ច័ន្ទនី ត្រូវបានចោទប្រកាន់ពីបទបង្កើតកំលាំងប្រដាប់អាវុធ ខុសច្បាប់ និងឆបោក ។

[១៣] ការចោទប្រកាន់ធ្ងន់ធ្ងរត្រូវបានធ្វើឡើងផ្អែកលើអត្ថបទសារព័ត៌មានមួយ និងខ្សែអាត់សំលេងខ្លីមួយ ពីប្រភពដែលគេមិនស្គាល់ ។

[១៤] Amnesty International USA, កម្ពុជា : សិទ្ធិក្នុងការទទួលបានការកាត់ទោសដោយយុត្តិធម៌ ត្រូវតែអនុវត្ត ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៥ http://www.amnestyusa.org/countries/cambodia/document.do?id=1CAD18FD4505ABBE802569A50071591C

ជាតិ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា សិទ្ធិនេះត្រូវបានគេមើលឃើញ ថាជាបុព្វសិទ្ធិដែលត្រូវបានពង្រីក និងដកចេញវិញដោយស្ថាប័ននីតិប្រតិបត្តិ ។ ជិតមួយឆ្នាំក្រោយមក អ្នកនយោបាយទាំងបីរូបនេះ បានទទួលអភ័យឯកសិទ្ធិសភាមកវិញក្រោយពីកិច្ចព្រមព្រៀងមួយត្រូវបានធ្វើឡើងរវាងប្រធានបក្សសំលេងជំទាស់ ឯកឧត្តម សម រង្ស៊ី និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។

ការវិលត្រឡប់មកវិញរបស់ឯកឧត្តម សម រង្ស៊ី និងការស្តារគណបក្សរបស់ឯកឧត្តម បានធ្វើអោយគណបក្សហ៊្វុនស៊ិនប៉ិចដែលជាដៃគូរក្នុងរដ្ឋាភិបាលចំរុះជាប្រពៃណីរបស់គណបក្សប្រជាជនកម្ពុជា (CPP) ខាតបង់យ៉ាងខ្លាំង។ រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាដែលត្រូវបានកែប្រែជាច្រើនរួចទៅហើយ កាលពីក្រោយការបោះឆ្នោតនៅក្នុងឆ្នាំ ១៩៩៨ និង ២00៣ ដើម្បីជួយគណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច ឈានដល់កិច្ចព្រមព្រៀងបែងចែកអំណាចនោះ ត្រូវបានធ្វើវិសោធនកម្មម្តងទៀត ។ នៅគ្រានេះ សំលេងភាគច្រើន ២ភាគ៣ ដែលត្រូវការ ដើម្បីបង្កើតរដ្ឋាភិបាលត្រូវបានលុបចោល និងយកសំលេង ៥0%បូក១ ជំនួសវិញដោយធ្វើអោយគណបក្សហ៊្វុនស៊ិនប៉ិចអស់ឥទ្ធិពលដែលនៅសេសសល់របស់ខ្លួន ។ នៅក្រោយការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ចុងក្រោយនេះ គណបក្សប្រជាជនកម្ពុជាបានចាត់វិធានការភ្លាមៗ ដើម្បីផាត់ចោលអតីតដៃគូរបស់ខ្លួនដោយបណ្តេញរដ្ឋមន្ត្រី រដ្ឋលេខាធិការ អភិបាលខេត្ត និងមន្ត្រីផ្សេងៗទៀតមកពីគណបក្សហ៊្វុន ស៊ិនប៉ិច។ ការធ្វើវិសោធនកម្មយ៉ាងប្រញាប់ប្រញាល់ដោយមិនបានស្ទាបស្ទង់មតិយោបល់ប្រជាពលរដ្ឋ ។ រដ្ឋធម្មនុញ្ញ ជាលាយលក្ខណ៏អក្សរត្រូវបានតាក់តែងឡើងក្នុងគោលបំណង ដើម្បីទ្រទ្រង់សង្គមប្រជាធិបតេយ្យមួយដែលមានស្ថិរភាព ហើយគួរត្រូវធ្វើវិសោធនកម្ម តែនៅក្រោយពេលដែលមានការពិភាក្សា ការពិគ្រោះយោបល់ និងការពិចារណាបានទូលំទូលាយតែប៉ុណ្ណោះ គឺមិនមែនដើម្បីបំពេញសេចក្តីត្រូវការផ្នែកនយោបាយរយៈពេលខ្លីនោះឡើយ ។ ការមិនគោរពចំពោះអ្នកតាក់តែងច្បាប់ បានស្តែងឡើងចំពោះស្ថាប័នមួយនេះ ធ្វើអោយប៉ះពាល់ដល់ស្ថិរភាពនាពេលអនាគត នៃប្រព័ន្ធរដ្ឋាភិបាលរបស់ប្រទេសកម្ពុជា ហើយជាទស្សនះតម្លាភាព និងការទទ្យលខុសត្រូវនៅមុខប្រជាពលរដ្ឋ។

ការចុះហត្ថលេខារបស់រដ្ឋាភិបាលកម្ពុជាលើសន្ធិសញ្ញាព្រំដែនបន្ថែមជាមួយប្រទេសវៀតណាម បានបំផុសអោយមានការពិភាក្សា យ៉ាងក្តៅគពន្ធនាគារនៅក្នុងប្រទេសកម្ពុជា ។ តាមប្រវត្តិសាស្ត្រ ទំនាក់ទំនងរវាងប្រទេសជិតខាងគ្នាទាំងពីរនេះ មានលក្ខណៈងាយប្រែប្រួល ហើយអាថិកំបាំងដែលគ្របពីលើសន្ធិសញ្ញាព្រំដែន បានធ្វើអោយសាធារណជនមិនអាចវាយតំលៃអំពីផលល្អរបស់សន្ធិសញ្ញានេះ នៅមុនពេលនៃការចុះហត្ថលេខាបានឡើយ។ នៅក្នុងប្រទេសដែលមានលទ្ធិប្រជាធិបតេយ្យរឹងមាំ ការដោះស្រាយបញ្ហាព្រំដែនអន្តរជាតិ ដែលមានជំលោះយូរអង្វែងនេះ នឹងត្រូវធ្វើឡើងព្រមគ្នានឹងការផ្តល់ព័ត៌មានជាសាធារណៈ និងការពិភាក្សា ។ ប៉ុន្តែ រដ្ឋាភិបាលបានបញ្ជាក់យ៉ាងច្បាស់ថា អ្នកដែលប្រឆាំងមិនអាចអត់ឱនអោយបានឡើយ នៅលើបញ្ហាដ៏រសើបនេះ ។ លោកនាយករដ្ឋមន្ត្រី[១៥] បានមានប្រសាសន៏ថា : "ចោទ ហ៊ុន សែន ថាលក់ទឹកដី មិនមែនជា រឿងលេងសើចឡើយ...ចាប់ពីពេលនេះតទៅ ខ្ញុំនឹងប្តឹងទាំងអស់ ទោះជាអ្នកណាក៏ដោយ មិនថាអ្នកនោះមានមុខតំណែងជាអ្វីទេ ។ ខ្ញុំត្រូវតែប្តឹង" ។

[១៥] លិខិតរបស់ព្រះអង្គម្ចាស់នរោត្តម រណប្ញទ្ធិ ថ្វាយអតីតព្រះមហាក្សត្រនរោត្តម សីហនុ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២00៥ http://www.funcinpec.org/SKP_letter_king_02-14-05.htm

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ អ្នករិះគន់នៅតែនិយាយ -ហើយបានទទួលរងនូវពិន័យ ។ លោក ម៉ម សូណង់ដូ ដែលជាអ្នកសារព័ត៌មាន និងជាម្ចាស់ស្ថានីយវិទ្យុសំបុកឃ្មុំ ត្រូវបានចាប់ខ្លួនពីបទបរិហារកេរ្តិ៍[១៦] នៅថ្ងៃទី១១ ខែតុលា ដោយសារបានចាក់ផ្សាយបទសំភាសន៏មួយជាមួយនឹងលោក ស៊ាន ប៉េងសែ[១៧] ដែលបានរិះគន់សន្ធិសញ្ញាព្រំដែន ។ នៅថ្ងៃដែលលោកម៉ម សូណង់ដូ ត្រូវបានចាប់ខ្លួនសមាជិកបួនរូប នៃក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា គឺ លោករ៉ុង ឈុន[១៨] លោកជា មុន្នី[១៩] លោកអៀ ចាន់ណា[២០] និងលោកម៉ែន ណាត[២១] បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៏មួយដែលអំពាវនាវអោយប្រជាពលរដ្ឋកម្ពុជា "ចូលរួមក្នុងការកាន់ទុក្ខសំរាប់គ្រោះថ្នាក់ធ្ងន់ធ្ងរ ចំពោះបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា "ហើយអំពាវនាវដល់សមាជិកសភា និងព្រះមហាក្សត្រសូមកុំផ្តល់ថ្វាយអនុម័តសន្ធិសញ្ញានោះ ។ តាមបញ្ជាលោកនាយករដ្ឋមន្ត្រី អ្នកទាំងបួនត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងញុះញង់[២២] ។ លោករ៉ុង ឈុន ត្រូវបានចាប់ និងឃុំខ្លួន ចំណែកឯសមាជិកបីរូបផ្សេងទៀត បានស្វះស្វែងរកកិច្ចការពារនៅក្រៅប្រទេស ។

អ្នករិះគន់សន្ធិសញ្ញាព្រំដែនផ្សេងទៀត ដែលត្រូវបានចោទប្រកាន់ នៅក្នុងការបង្ក្រាបលើក្រុមអ្នកប្រឆាំង រួមមានព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ និងបណ្ឌិត សាយ បូរី ដែលជាទីប្រឹក្សារបស់អតីតព្រះមហាក្សត្រសម្តេចព្រះនរោត្តម សីហនុ ។ ជំនាញការផ្នែកច្បាប់បានមានប្រសាសន៏ថា ហេតុផលនៃការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ មានភាពមិនត្រឹមត្រូវយ៉ាងខ្លាំង ដោយសារតែសេចក្តីអត្ថាធិប្បាយរបស់ចុងចោទបានផ្តោតសំខាន់ទៅលើគោលនយោបាយ មិនមែនទៅលើបុគ្គលទេ ហើយនៅក្នុងករណីរបស់លោក ម៉ម សូណង់ដូ លោកត្រូវបានគេចោទប្រកាន់ដោយសារតែទស្សនៈរបស់ភ្ញៀវរបស់លោក ។

ការចាប់ខ្លួនទាំងនេះ គឺជាការបង្ក្រាបជាលក្ខណៈប្រព័ន្ធ ទៅលើសេរីភាពក្នុងការបញ្ចេញមតិ ដែលជាសិទ្ធិមនុស្សជាមូលដ្ឋាន ។ បញ្ហាសន្ធិសញ្ញាព្រំដែន គឺជាចំណាប់អារម្មណ៏ស្របច្បាប់របស់សាធារណជន ហើយកង្វះតម្លាភាព ឬការពិភាក្សាអំពីសន្ធិសញ្ញានេះ បានគូសបញ្ជាក់អោយឃើញពីការថមថយនៃលទ្ធិប្រជាធិប្បតេយ្យ ។ ការបង្ក្រាបនេះ ក៏បង្ហាញអោយឃើញផងដែរថា អង្គនីតិប្រតិបត្តិកំពុងជ្រៀតជ្រែកដោយបើកចំហក្នុងកិច្ចការរបស់ស្ថាប័នតុលាការ ។

---

[១៦] ដោយ Pin Sisovann, Phann Ana and Lee Berthiaume, *នាយករដ្ឋមន្ត្រីមានប្រសាសន៍ថា លោកនឹងប្តឹងអ្នកណាមួយ ដែលនិយាយពីរឿងព្រំដែន* កាសែត ឌឹ ឃែមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ ។

[១៧] ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជា (ដែលមានមូលដ្ឋាននៅក្នុងប្រទេសបារាំង) ការចោទប្រកាន់ដំបូង គឺពីបទបរិហារកេរ្តិ៍ ប៉ុន្តែការចោទប្រកាន់ពីបទញុះញង់ និងផ្សាយព័ត៌មានមិនពិតត្រូវបានបន្ថែម នៅពេលក្រោយមកទៀត ។

[១៨] លោករ៉ុង ឈុន ក៏ជាប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យផងដែរ ។

[១៩] ជា មុន្នី ក៏ជាប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ។

[២០] អគ្គលេខាធិការរងនៃចលនានិស្សិតដើម្បីលទ្ធិប្រជាធិបតេយ្យ ។

[២១] ប្រធាន សមាគមមន្ត្រីរាជការកម្ពុជាឯករាជ្យ ។

[២២] ការចោទប្រកាន់ គឺក្រោមមាត្រាទី ៦០ នៃច្បាប់អ៊ុនតាក់ "ការញុះញង់ដែលមិនបង្កដល់ការប្រព្រឹត្តបទឧក្រិដ្ឋ ឬបទល្មើសមជ្ឈឹម" ។

នៅថ្ងៃទី១០ ខែធ្នូ អង្គការមិនមែនរដ្ឋាភិបាលនានា បានប្រមូលផ្តុំនៅឯពហុកីឡាដ្ឋានជាតិអូឡាំពិក នៅក្នុងទីក្រុងភ្នំពេញ ដើម្បីប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) បានចងបដាជាច្រើននៅក្នុងរោងរបស់ខ្លួន ក្នុងនោះរួមទាំងបដា មួយដែលធ្លាប់ត្រូវបានប្រើប្រាស់នៅមុនការបោះឆ្នោតជាតិឆ្នាំ ២០០៣ ដែលនៅលើបដានោះ អ្នកភូមិបានសរសេរមតិយោបល់របស់ពួកគេ ។

ក្នុងចំណោមសារជាច្រើននោះ មានសារមួយដែលបានសរសេរចោទរដ្ឋាភិបាលថាជា "របបក្បត់ជាតិដែលលក់ទឹកដីអោយប្រទេសវៀតណាម" ។ នគរបាលបានចាប់ផ្តើមថតរូបភាពបដានោះ បុគ្គលិក CCHR បានដកបដានោះចេញភ្លាមៗដោយខ្លាចការសងសឹក ។ ប៉ុន្តែការដកបដាចេញ ទំនងជាយឺតពេលពេកទៅហើយ ។ នៅក្នុងរយៈ ពេលមួយខែ លោក កឹម សុខា ប្រធាន CCHR លោក ប៉ា ងួនទៀង នាយកកម្មវិធីវិទ្យុសំលេងប្រជាធិបតេយ្យ របស់ CCHR និងលោក យ៉េង វីរៈ នាយកប្រតិបត្តិ នៃមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៏ (CLEC) ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ទាក់ទង នឹងបដា ហើយត្រូវបានចាប់ខ្លួន ។ ជាថ្មីម្តងទៀត ការចាប់ខ្លួននេះបានបង្ហាញអោយឃើញពីការជ្រៀតជ្រែករបស់អង្គនីតិប្រតិបត្តិនៅក្នុងកិច្ចការរបស់ស្ថាប័នតុលាការ ព្រមទាំងការប្រើប្រាស់បទបរិហារកេរ្តិ៍ ដើម្បីចាប់មនុស្សដាក់ពន្ធនាគារ និងការបំបិទមាត់អ្នករិះគន់ ។ ដោយមានឥស្សរជនបក្សប្រឆាំង និងអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ ជាច្រើនរូបត្រូវស្ថិតក្នុងពន្ធនាគារ ឬនិរទេសខ្លួនដោយខ្លួនឯងបណ្តឹងពីបទបរិហារកេរ្តិ៍ បានធ្វើអោយសង្គមស៊ីវិលមានការភ័យខ្លាច និងច្របូកច្របល់ ។



ហ្វូងមនុស្សរង់ចាំទទួលការមកដល់របស់បុគ្គល ៥រូប ដែលត្រូវបានដោះលែង អោយនៅក្រៅឃុំជាបណ្តោះអាសន្ន កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៦ ។

នៅក្នុងខែមករា ឆ្នាំ២០០៦ ដោយមានអន្តរាគមន៏យ៉ាងខ្លាំងក្លាពីសំណាក់សហគមន៏អន្តរជាតិ និងអង្គការក្នុងស្រុក លោក យ៉េង វីរៈ ត្រូវបានដោះលែងអោយនៅក្រៅឃុំបណ្តោះអាសន្នមុនគេ ហើយក្រោយមកទៀត គឺមាន លោក ម៉ម សូណង់ដូ លោក កឹម សុខា លោក រ៉ុង ឈុន និង លោក ប៉ា ងួនទៀង (ក្រោយពីជំនួបប្រជុំរវាងនាយករដ្ឋមន្ត្រី និងលោកឯកអគ្គរដ្ឋទូត Christopher Hill ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកទទួលបន្ទុកការិយាល័យអាស៊ីបូព៌ា និងកិច្ចការសាធារណៈ) ។

ប៉ុន្តែការចោទប្រកាន់ប្រឆាំងនឹងអ្នកទាំង នេះនៅតែមានសុពលភាពនៅឡើយ ។ ក្រោយមកក៏មានយុទ្ធសាស្ត្រមួយទៀត ដោយប្រើប្រាស់ការចោទប្រកាន់ដែលរង់ចាំការកាត់ទោស ជាការគំរាមកំហែងអូសបន្លាយចំពោះអ្នករិះគន់រដ្ឋាភិបាល ។ ឧទាហរណ៏ ការចោទប្រកាន់ប្រកាន់លើរូបលោក ម៉ម សូណង់ដូ នៅក្រោយពេលកើតមានកុប្បកម្មនាឆ្នាំ ២០០៣ កំពុងស្ថិតនៅមុខតុលាការនៅឡើយ ។ ខណៈដែលទង្វើនេះ ផ្ទុយពីគោលការណ៏នៃនីតិវិធីច្បាប់ និងយុត្តិធម៌មិនទាន់ពេលវេលា ការចោទប្រកាន់ដែលមិនទាន់ដាច់ស្រេចនេះនៅតែមានដដែល ទោះបី

ជាតាមច្បាប់របស់ប្រទេសកម្ពុជា លោក ម៉ម សូណង់ដូ មិនអាចត្រូវកាត់ទោសពីបទចោទប្រកាន់ទាំងនោះទៀតឡើយ[២៣] ។

ក្រៅពីនេះ ពេលវេលានៃការដោះលែងអ្នកទាំងនេះមានសារៈសំខាន់ណាស់ គឺកើតឡើងក្នុងពេលតែប៉ុន្មានសប្តាហ៍ប៉ុណ្ណោះ នៅមុនជំនួបប្រជុំរវាងរដ្ឋាភិបាល និងក្រុមពិគ្រោះយោបល់របស់ម្ចាស់ជំនួយនាខែមីនា ដែលក្នុងជំនួបប្រជុំនោះ ទីភ្នាក់ងារជំនួយនឹងសន្យា ផ្តល់វិភាគទានរបស់ខ្លួនសំរាប់ឆ្នាំខាងមុខ ។ ការវិវឌ្ឍនេះ ត្រូវបានអបអរសាទរដោយម្ចាស់ជំនួយ និងអ្នកការទូត ហើយប្រាក់ជំនួយ ៦០១លានដុល្លារ ត្រូវបានសន្យាផ្តល់អោយសំរាប់ឆ្នាំ ២០០៦ ។ ទោះបីការដោះលែងពីពន្ធនាគារត្រូវបានស្វាគមន៍ក៏ដោយ តែការដោះលែងអោយនៅក្រៅឃុំបណ្តោះអាសន្ននូវមនុស្សដែលមិនគួរត្រូវចោទប្រកាន់ និងឃុំឃាំងពុំគួរត្រូវបានគេចាត់ទុកថាជាភាពជឿនលឿនដ៏មានអត្ថន័យនោះឡើយ ។ ផ្ទុយទៅវិញការចាប់ខ្លួន និងការឃុំឃាំងពីដំបូង (ព្រមទាំងការដោះលែងនៅពេលក្រោយមក) បានបង្ហាញអោយឃើញយ៉ាងច្បាស់នូវការជ្រៀតជ្រែករបស់អង្គនីតិប្រតិបត្តិក្នុងកិច្ចការរបស់ស្ថាប័នតុលាការ ។ ការបង្រ្កាបលើអ្នកជំទាស់ បានឆ្លុះបញ្ចាំងអោយឃើញអំពីភាពផុយស្រួយ នៃសេរីភាពក្នុងការសំដែងមតិ នីតិរដ្ឋ និងសិទ្ធិមនុស្សនៅកម្ពុជា ។




នគរបាលអន្តរាគមនបានរារាំងកម្មករមិនអោយចូលរកូងភ្នំពេញ ក្នុងទិវាពលកម អន្តរជាតិ លាកពិថ្ងៃ ទី ២០០៦

នាយករដ្ឋមន្ត្រីមិនទាន់បានធ្វើអោយចប់ចុងចប់ដើមនូវការអំពាវនាវដ៏គួរអោយភ្ញាក់ផ្អើលរបស់លោក នៅមុនកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់ ក្នុងការលុបបទបរិហារកេរ្តិ៍ចេញពីទោសព្រហ្មទណ្ឌទេ ។ ទោះបីជាវិធានការដែលទទួលបានការស្វាគមន៍ ត្រូវបានធ្វើឡើងនៅពេលក្រោយមកដើម្បីលុបចោលនូវការដាក់ទោសអោយជាប់ពន្ធនាគារក្តី ក៏បទបរិហារកេរ្តិ៍នៅតែជាបទ ល្មើសព្រហ្មទណ្ឌដដែល ហើយការលុបចោលនូវការដាក់ទោសអោយជាប់ពន្ធនាគារមិនបានកាត់បន្ថយមធ្យោបាយផ្លូវច្បាប់របស់រដ្ឋាភិបាលក្នុងការចាប់អ្នករិះគន់ខ្លួនដាក់ពន្ធនាគារឡើយ ។ មេដឹកនាំសង្គមស៊ីវិលមួយចំនួន ដែលត្រូវបានចាប់ខ្លួនដោយសារកិច្ចការព្រំដែន ហើយត្រូវបានចោទប្រកាន់មិនត្រឹមតែពីបទបរិហារកេរ្តិ៍ប៉ុណ្ណោះទេ ប៉ុន្តែពីបទញុះញង់ផង ដែរលោក ម៉ម សូណង់ដូ ក៏ត្រូវបានចោទប្រកាន់ថែមទៀតពីបទផ្សាយព័ត៌មានមិនពិត ដែលបទចោទប្រកាន់ទាំងពីរនេះមានទំងន់ទោសជាប់ពន្ធនាគាររឹតតែយូរជាងទោសព្រហ្មទណ្ឌបរិហារកេរ្តិ៍ដែលគេចោទពីដំបូងទៅទៀត ។ ជាងនេះទៅទៀត ដោយសារច្បាប់កម្ពុជាអនុញ្ញាតអោយដាក់ពន្ធនាគារនូវអ្នកដែលជំពាក់បំណុលគេនោះគ្មានអ្វី ដែលនឹងអាចរារាំងតុលាការមិនអោយដាក់ទោសដោយបង់ពិន័យជាប្រាក់ច្រើន ដោយមិនសមហេតុផលក្នុងករណីបរិហារកេរ្តិ៍ឡើយហេតុដូច្នេះ ការដាក់ពន្ធនាគារនៅតែមានជាដដែល ។

[២៣] ច្បាប់ព្រហ្មទណ្ឌបរិហារកេរ្តិ៍ ត្រូវបានយកចេញពីច្បាប់របស់អ៊ុនតាក់ ដែលបានអនុម័តអោយប្រើប្រាស់ នាឆ្នាំ១៩៩២ ។ ច្បាប់សារព័ត៌មាន ដែលអនុម័តអោយប្រើប្រាស់ នៅក្នុងឆ្នាំ១៩៩៩ ជំនួសច្បាប់នេះ ហើយមិនចាត់ទុកបទបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌឡើយ ប៉ុន្តែជារឿយៗ ច្បាប់នេះមិនត្រូវបានយកមកប្រើទេ ដោយប្រើច្បាប់អ៊ុនតាក់វិញ ដែលមានការដាក់ទោសទណ្ឌធ្ងន់ធ្ងរជាង ។

គេនៅរង់ចាំមើលផងដែរថា តើការដាក់ទោសទណ្ឌអោយជាប់ពន្ធនាគារ នៅតែមានសំរាប់បទព្រហ្មទណ្ឌបរិហារកេរ្តិ៍ ឬយ៉ាងណានោះ នៅក្នុងក្រមព្រហ្មទណ្ឌដែលត្រូវកែប្រែនៅពេលខាងមុខនេះ ដែលច្បាប់នេះត្រូវបានរិះគន់រួចទៅហើយ ពីការមិនសូវគោរពដល់សេរីភាពជាមូលដ្ឋាន និងសេរីភាពប្រជាធិបតេយ្យ (ឧទាហរណ៍ៈ សេចក្តីព្រាងនៃ ខ មួយអនុញ្ញាតអោយមានការកាត់ទោសអោយជាប់ពន្ធនាគារពីបទរិះគន់ចៅក្រម) ។ ច្បាប់ផ្សេងទៀតរួមមានច្បាប់ថ្មីស្តីពីការប្រមូលផ្តុំជាសាធារណៈ ដែលគំរាមរឹតត្បិតការប្រមូលផ្តុំភាគច្រើនបំផុត អោយធ្វើនៅលើ "ទីធ្លាសេរីភាព" ដែលកំណត់ដោយរដ្ឋាភិបាល និងសេចក្តីស្នើច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល ដែលអាចនឹងរឹតត្បិតលទ្ធភាពនៃការប្រតិបត្តិការរបស់អង្គការសិទ្ធិមនុស្សកម្ពុជា និងសមាគមផ្សេងៗទៀត ។

នាពេលបច្ចុប្បន្ននេះ រដ្ឋាភិបាលកម្ពុជាបន្តប្រើប្រាស់បរាជ័យរបស់ខ្លួន ក្នុងការទប់ស្កាត់កុប្បកម្មនាខែមករា ឆ្នាំ២០០៣ ជាលេសសំរាប់ការហាមឃាត់ស្ទើរតែគ្រប់ការតវ៉ាការប្រមូលផ្តុំ និងការដង្ហែក្បួនដោយសន្តិវិធីទាំងអស់ ។ នៅក្នុងឆ្នាំ២០០៥ លីកាដូ បានកត់ត្រាឃើញថា ៤០ករណី នៃការធ្វើបាតុកម្មដោយសន្តិវិធីត្រូវបានបដិសេធន៍ការអនុញ្ញាត ឬត្រូវបានបំបែកដោយនគរបាល[២៤] ។

ការតវ៉ាចំនួន ១៨ករណី ជាប់ទាក់ទងនឹងជំលោះដីធ្លី និង ៩ករណី គឺជាកូដកម្មរោងចក្រ ឬការជួបជុំគ្នារបស់សហជីព ។ យោងតាមលីកាដូ និងប្រភពប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ១៦ករណី នៃព្រឹត្តិការណ៍ទាំងអស់ជាប់ពាក់ព័ន្ធនឹងអំពើហិង្សាធ្ងន់ធ្ងរដោយនគរបាល ឬកងរាជអាវុធហត្ថ ។ការរឹតត្បិតសេរីភាពជាមូលដ្ឋាន នៅតែបន្តនៅក្នុងឆ្នាំ ២០០៦ ដោយនគរបាលប្រឆាំងកុប្បកម្មរាប់រយនាក់ បានធ្វើការបិទផ្លូវសំខាន់ៗចូលក្នុងទីក្រុងភ្នំពេញ ក្នុងកិច្ចប្រឹងប្រែងដើម្បីរារាំងកម្មកររោងចក្រកាត់ដេរ មិនអោយប្រារព្ធទិវាពលកម្មអន្តរជាតិនៅក្នុងទីក្រុង ។ ការរឹតត្បិតលើសេរីភាពក្នុងការធ្វើដំណើរ ក៏ត្រូវបានជួបប្រទះផងដែរ ដោយសកម្មជនសហគមន៍ នៅក្នុងខេត្តរតនគីរី និងមណ្ឌលគីរី ដែលត្រូវគេតំរូវអោយសុំការអនុញ្ញាត ពីអាជ្ញាធរមូលដ្ឋាន ដើម្បីចាកចេញពីភូមិ ។ ការធ្វើដំណើរ ដោយមិនសុំការអនុញ្ញាតនឹងទទួលរងនូវការគំរាមកំហែង ការឃាយី និងការបំភិតបំភ័យ។ ការរឹតត្បិតទាំងនេះ រំលោភលើសិទ្ធិជាមូលដ្ឋានដែលត្រូវបានកំណត់នៅក្នុងច្បាប់អន្តរជាតិ និងរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា ។

ការចាប់ខ្លួនអ្នករិះគន់រដ្ឋាភិបាល និងការបន្តរឹតត្បិតសេរីភាព ក្នុងការប្រមូលផ្តុំ និងការបញ្ចេញមតិ បានជះឥទ្ធិពលអាក្រក់ទៅលើចលនាសហជីពដ៏ក្មេងខ្ចី អង្គការមិនមែនរដ្ឋាភិបាលជាទូទៅ និងសង្គមស៊ីវិលដោយប្រយោល ។ ទាំងអស់គ្នាដឹងច្បាស់ណាស់អំពីភាពងាយស្រួល ដែលរដ្ឋាភិបាលអាចចេញបញ្ជាអោយចាប់អ្នករិះគន់ដាក់ពន្ធនាគារ ហើយការគំរាមកំហែងដោយប្រយោលប៉ះពាល់ដល់ឆន្ទៈ និងលទ្ធភាពរបស់ពួកគេក្នុងការធ្វើអត្ថាធិប្បាយជាសាធារណលើបញ្ហាសំខាន់ៗ និងគោលនយោបាយរបស់រដ្ឋាភិបាល ។ បើគ្មានសេរីភាពក្នុងការបញ្ចេញ

---

[២៤] ច្បាប់អ៊ុនតាក់ (មាត្រាទី ២១) ចែងថា "ជនជាប់ចោទ ទោះបីជាស្ថិតនៅក្នុង ឬមិនស្ថិតនៅក្នុងការឃុំឃាំងក៏ដោយ ត្រូវតែវិនិច្ឆ័យទោសក្នុងរយៈពេលមិនលើសពី ៦ខែ ឡើយ ក្រោយពេលចាប់ខ្លួន" ។

មតិ និងការពិភាក្សាទេនោះ លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា គឺមានតែនៅសំបកក្រៅសុទ្ធសាធ រីឯខាងក្នុង គឺពោរពេញដោយការភ័យខ្លាច និងការបង្ក្រាប ។

# និទ្ទណ្ឌភាព

ការមិនចាត់វិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីនាំយកទៅកាត់ទោសនូវមន្ត្រីនគរបាល ទាហាន និងមន្ត្រីរដ្ឋាភិបាល ដែលប្រព្រឹត្តការរំលោភសិទ្ធិមនុស្ស បន្តធ្វើអោយអន្តរាយយ៉ាងធ្ងន់ធ្ងរដល់ស្មារតីយុត្តិធមិសាធារណៈ នៅក្នុងប្រទេសកម្ពុជា ។ ផ្ទុយទៅវិញ និទ្ទណ្ឌភាពនោះជំរុញជាលក្ខណៈប្រព័ន្ធ អោយមានបរិយាកាសមួយដែលបុគ្គលមានអំណាចចាត់ទុកខ្លួនគេនៅពីលើច្បាប់ ហើយត្រូវបានគេចាត់ទុកយ៉ាងដូច្នេះមែន ។

ការកើតមាននិទ្ទណ្ឌភាពដ៏រាលដាល និងផលប៉ះពាល់ដ៏អាក្រក់នៃទង្វើទៅលើលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ត្រូវបានកត់ត្រាយ៉ាងគ្រប់គ្រាន់នៅក្នុងឯកសារ[២៥] ។ ករណីមួយដែលបានកើតឡើងនាពេលថ្មីៗកន្លងទៅនេះ គឺការបាញ់អ្នកភូមិ ៥នាក់ នៅភូមិ ក្បាលស្ពានដូចដែលបានលើកឡើងពីខាងលើ ។ ទោះបីជាមានសាក្សីដែលបានឃើញហេតុការណ៍រាប់រយនាក់ ក៏គ្មានជនណាម្នាក់បានជាប់ទោសដោយអំពើមនុស្សឃាតនេះឡើយ។ តុលាការខេត្តបាត់ដំបងបានធ្វើការលើកលែងការចោទប្រកាន់ប្រឆាំងនឹងមន្ត្រីនគរបាលចំនួន ៣រូប បានត្រូវដោះលែងពួកគេពីការឃុំឃាំង។ ករណីនេះត្រូវបានបញ្ចប់ជាស្ថាពរ ហើយសារដំណឹងដ៏ច្បាស់លាស់សំរាប់អ្នកភូមិក្បាលស្ពាន ព្រមទាំងអ្នកផ្សេងទៀត ដែលពាក់ព័ន្ធនៅក្នុងជំលោះដីធ្លី គឺថាអំពើហិង្សា និងជាវិធីដោះស្រាយជំលោះដែលអាចត្រូវទទួលយក។

ប្រវត្តិសាស្ត្រថ្មីៗរបស់ប្រទេសកម្ពុជាក៏ធ្លាប់កើតមាននូវឧបទ្ទវហេតុស្រដៀងៗគ្នានេះដែរ ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៤ ការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (UNCOHCHR) បានបញ្ជូនបញ្ជីករណីនិទណ្ឌភាពចំនួន ១៧៨ ករណី ដែលកត់ត្រាជាឯកសារដោយតំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្សចាប់តាំងពីឆ្នាំ ១៩៩២ មក[២៦] ។ តារាងបញ្ជី "តំណាងពិសេសទទួលបន្ទុកសិទ្ធិមនុស្ស" (មិនពេញលេញ) នេះរួមមានការសំលាប់ដែលបណ្តាលមកពីហេតុផលនយោបាយ ការធ្វើទារុណកម្ម និងការជួញដូរមនុស្ស និងបានបង្ហាញអោយឃើញអំពី "គំរូដែលមានភាពស៊ីសង្វាក់គ្នានៃការយឺតយ៉ាវ និងកង្វះឆន្ទៈនៅក្នុងការស៊ើបអង្កេត ការកសាងសំណុំរឿងដើម្បីវិនិច្ឆ័យទោស និងការកាត់ទោសនូវអ្នកដែលពាក់ព័ន្ធ"[២៧] ។

---

[២៥] សំរាប់ឧទាហរណ៍ ចូរមើលរបាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការអ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា *គំរូនៅតែបន្តនៃនិទណ្ឌភាពនៅកម្ពុជា* ខែតុលា ឆ្នាំ២០០៥ និងរបាយការណ៍ Adhoc លីកាដូ និង Human Rights Watch *និទ្ទណ្ឌភាពនៅកម្ពុជា : របៀបដែលអ្នករំលោភសិទ្ធិមនុស្ស គេចពីសំណាញ់យុត្តិធម៌* ខែមិថុនា ឆ្នាំ១៩៩៥ ទំព័រ ១៤ ។

[២៦] របាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការអ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា *គំរូនៅតែបន្តនៃនិទ្ទណ្ឌភាពនៅកម្ពុជា* ខែតុលា ឆ្នាំ២០០៥ ទំព័រ១៤ ។

[២៧] លីកាដូ *ការរឹតត្បិតសេរីភាពក្នុងការប្រមូលផ្តុំ នៅកម្ពុជា* របាយការណ៍សង្ខេប ឆ្នាំ២០០៥ ។

លំនាំនេះត្រូវបានបញ្ជាក់ថាពិតប្រាកដ ដោយការឆ្លើយតបពីក្រសួងមហាផ្ទៃដែលធ្វើឡើងនៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៤[២៨] ។ ក្រសួងបានជំរាប UNCOHCHR ថា ២៥ករណី គឺទាក់ទងនឹងរដ្ឋប្រហារ ខែកក្កដា ឆ្នាំ១៩៩៧ ( ហេតុដូច្នេះហើយ ត្រូវបានចាត់ទុកថា ស្ថិតនៅក្រៅអាណត្តិនៃប្រព័ន្ធច្បាប់) ៤ករណី បានកើតឡើងនៅក្នុងតំបន់ដែលត្រួតត្រាដោយខ្មែរក្រហម និងបានអះអាងថា ២ ករណីមិនបានកើតឡើងទេ ហេតុដូច្នេះហើយ គ្មានវិធានការណាមួយដែលនឹងត្រូវអនុវត្តឡើយ ។ ក្នុងចំណោម ៦១ករណី ដែលបានបញ្ជូនដល់ដៃតុលាការ ១៧ករណី ត្រូវបានលើកលែងការចោទប្រកាន់ជនសង្ស័យ ៩ នាក់រត់គេចខ្លួន និង ១៦ ករណី ត្រូវបានផ្តន្ទាទោស ( ប៉ុន្តែទោះជាយ៉ាងនេះក្តី ករណីខ្លះត្រូវបានកាត់ទោសដោយកំបាំងមុខ ដែលជាក់ស្តែងដូចគ្នាទៅនឹង "ការព្យួរទោស" ចំណែកឯអ្នកផ្សេងមួយចំនួនទៀត ត្រូវបានកាត់ទោសដោយមិនសមស្របយោងតាមអង្គការសហប្រជាជាតិ) ។

១៩ ករណីផ្សេងទៀត កំពុងស្ថិតនៅក្នុងដៃតុលាការនៅឡើយ ហើយ ៦៤ករណីទៀតកំពុងស្ថិតក្នុងការស៊ើបអង្កេតបន្ត ថ្វីត្បិតបើករណីទាំងអស់នេះបានកើតឡើងយូរឆ្នាំកន្លងមកហើយក្តី ។

របាយការណ៍ UNCOHCHR បានធ្វើការសន្និដ្ឋានថា "ប្រទេសកម្ពុជាពុំទាន់បង្កើតស្ថាប័នរដ្ឋ អោយមានភាពអព្យាក្រឹត្យ ប្រព័ន្ធត្រួតពិនិត្យអំណាចនីតិប្រតិបត្តិ និងយន្តការ ដើម្បីពង្រឹងការអនុវត្តសិទ្ធិ ដូចដែលត្រូវបានធានានៅក្នុងច្បាប់ និងរដ្ឋធម្មនុញ្ញនៅឡើយ"[២៩] ។ ខណៈដែលបញ្ជី ១៧៨ ករណី នេះផ្តោតសំខាន់ទៅលើគំរូករណីនិទ្ទណ្ឌភាពធំៗបំផុតដែលកើតមាននៅក្នុងទសវត្សរ៍កន្លងទៅ ភាគច្រើននៃការរកឃើញ គឺស្របគ្នានឹងបទពិសោធន៍ប្រចាំថ្ងៃរបស់លីកាដូ នៅក្នុងឆ្នាំ ២០០៦ ។

និទ្ទណ្ឌភាពនៅក្នុងប្រទេសកម្ពុជា រីកធំធាត់នៅលើទំនាក់ទំនងដែលមានលក្ខណៈសហប្រតិបត្តិការគ្នារវាងអ្នកដែលមានអំណាចផ្នែកនយោបាយ និងសេដ្ឋកិច្ច និងកងកំលាំងប្រដាប់អាវុធ និងនគរបាល ។

មន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ខ្លះ អ្នកជំនួញដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភខ្លះ មន្ត្រីយោធា និងនគរបាលជាន់ខ្ពស់ខ្លះ ប្រើប្រាស់កំលាំងសន្តិសុខដើម្បីអនុវត្តរបៀបវារៈនយោបាយរបស់ខ្លួន[៣០] ឬធ្វើសកម្មភាពខុសច្បាប់[៣១] ។ ជាការតបស្នងចំពោះភក្តីភាពរបស់ពួកគេ នគរបាល និងទាហានដែលមានឋានន្តរៈស័ក្តិទាប ត្រូវបានចៅហ្វាយនាយរបស់ខ្លួនផ្តល់នូវសេរីភាព ដើម្បីរំលោភច្បាប់ដោយគ្មានការខ្លាចរអាចំពោះទណ្ឌកម្មផ្លូវច្បាប់ ។ អ្នកដែលទទួលរង នូវអំពើរំលោភសិទ្ធិមនុស្សទាំងនេះ ជាធម្មតាសុទ្ធសឹងជាអ្នកក្រីក្រ ឬអ្នកដែលតំរាមកំហែង

---

[២៨] Lbid. ទំព័រ ៣៣ Lbid. ទំព័រ ១៤ និងឧបសម្ព័ន្ធ ខ ។

[២៩] lbid. ទំព័រ ៣៣

[៣០] ឧទាហរណ៍ដ៏ច្បាស់លាស់បំផុតនៃបញ្ហានេះ គឺអង្គភាពអង្គរក្សដែលមានទាហាន ១.០០០នាក់ ដែលយកចេញពីកងពលលេខ ៧០ នៃកងយោធពលខេមរភូមិន្ទ ដែលដើរតួជាកងទ័ពផ្ទាល់ខ្លួនសំរាប់នាយករដ្ឋមន្ត្រី ។

[៣១] ដើម្បីស្វែងយល់អំពីការពឹងផ្អែកលើគ្នាទៅវិញទៅមករវាងរវជននយោបាយ យោធា និងនគរបាល នៅក្នុងវិស័យកាប់ឈើ ចូរមើលរបាយ ការណ៍របស់ Global Witness *ចោរឯកសណ្ឋាន : អំពើពុករលួយជាលក្ខណៈស្ថាប័ន និងការកាប់ឈើខុសច្បាប់នៅជំរកសត្វព្រៃឱរ៉ាល់របស់ កម្ពុជា* ខែវិច្ឆិកា ឆ្នាំ២០០៤ ។

ចំពោះការគ្រប់គ្រងអំណាចរបស់ក្រុមដែលកំពុងកាន់កាប់អំណាច ។ ជារឿយៗ នគរបាល និងយោធាដើរតួជាកាំភ្លើងសំរាប់ជួលចំពោះអ្នកដែលមានលុយ ឬ ឥទ្ធិពលដោយមិនអើពើចំពោះគោលគំនិតនៃការអនុវត្តន៍ច្បាប់ប្រកបដោយយុត្តិធម៌សំរាប់ពលរដ្ឋគ្រប់រូប ។

ការរំលោភបំពានជាលក្ខណៈប្រព័ន្ធពីសំណាក់នគរបាល ដូចជាការធ្វើទារុណកម្ម និងការគំរាមយកប្រាក់ កើតមានជារឿយៗនៅក្នុងការស៊ើបអង្កេតបទឧក្រិដ្ឋដែលគេសង្ស័យ ។

ក្នុងរវាងពីខែមករា ឆ្នាំ២០០០ ដល់ខែវិច្ឆិកា ឆ្នាំ២០០៥ លីកាដូបានទទួលពាក្យបណ្តឹង ១៤៥ ករណីអំពីការធ្វើទារុណកម្មដោយអ្នក ដែលមានតួនាទីអនុវត្តច្បាប់ និងភ្នាក់ងាររដ្ឋទៃទៀតរបស់រដ្ឋ ប៉ុន្តែ ក្នុងចំណោមករណី ទាំងអស់នេះមានតែមួយករណីប៉ុណ្ណោះ ដែលទទួលបានការផ្តន្ទាទោសជនល្មើស ។ ករណីនេះ គឺនៅខេត្តស្វាយរៀង ដែលនៅទីនោះមន្រ្តីនគរបាល ៣ រូប ត្រូវបានផ្តន្ទាទោសពីបទបង្ករបួសស្នាម និងត្រូវបានកាត់អោយជាប់ពន្ធនាគារ ៣ខែ ដោយព្យួរទោសកាលពីខែមេសា ឆ្នាំ២០០២ ពីបទធ្វើទារុណកម្មលើកុមារពីររូប ។ នេះជាប្រវត្តិសាស្រ្ត ដែលការកាត់ទោសដោយបន្ធូរបន្ថយបែបនេះ គឺជារឿងធម្មតាទៅហើយនៅក្នុងករណីដ៏តិចតួចបំផុត ដែលមន្រ្តីនគរបាលត្រូវបានផ្តន្ទាទោសពីបទធ្វើទារុណកម្ម ។

ករណីដែលគេបានដឹងចុងក្រោយគេបំផុត អំពីនគរបាលម្នាក់ដែលជាប់ពន្ធនាគារ ជាទណ្ឌកម្មចំពោះការប្រព្រឹត្តទារុណកម្ម គឺនៅក្នុងឆ្នាំ ១៩៩៩ នៅពេលដែលមន្រ្តីកងរាជអាវុធហត្ថខេត្តព្រៃវែងម្នាក់ជាប់ក្នុងពន្ធនាគារអស់រយៈពេល ៤ខែ ដោយសារការវាយធ្វើបាបក្មេងប្រុស អាយុ ១៣ឆ្នាំម្នាក់ ដែលបានស្លាប់នៅក្នុងអំឡុងពេលនៃការសួរចំលើយ ។

មន្រ្តីនគរបាលជាច្រើននៅតែបន្តជឿជាក់ថា ការវាយធ្វើបាប និងការធ្វើទារុណកម្មក្នុងទំរង់ផ្សេងៗទៀត គឺជាវិធីស្របច្បាប់ ដើម្បីបានចំលើយសារភាព ។

ការធ្វើទារុណកម្ម ឬការគំរាមធ្វើទារុណកម្ម ក៏ត្រូវបាននគរបាលមួយចំនួនប្រើប្រាស់ផងដែរ ដើម្បីគំរាមយកប្រាក់ ពីជនដែលត្រូវបានចាប់ខ្លួន ជាថ្នូរនឹងការដោះលែង ។ មូលហេតុចំបងដែលការធ្វើទារុណកម្មនៅ តែត្រូវបានប្រើប្រាស់ដោយនគរបាលខ្លះ (ជាពិសេសដោយឆ្មាំពន្ធនាគារ ជាអ្នកដាក់ទណ្ឌកម្មចំពោះអ្នកទោស ដែលព្យាយាមរត់ចេញ) គឺដោយសារតែពួកគេអាចរួចខ្លួនមិនមានទោសពៃរ៍ពីទង្វើនេះ ។ អំពើនេះត្រូវបានលើកទឹកចិត្តដោយកង្វះ នៃការផ្តន្ទាទោសអ្នកដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្ម និងការទទួលយកដោយឥតសង្ស័យរបស់តុលាការនូវចំលើយសារភាព ដែលធ្វើឡើងដោយការបង្ខិតបង្ខំ ។

អំពើពុករលួយ ជួយសំរួលដល់និទ្ទណ្ឌភាព ។

នគរបាល និងមន្រ្តីតុលាការខ្លះទទួលយកប្រាក់ពីជនរងគ្រោះផង និងពីជនល្មើសសង្ស័យផងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ហើយ "យុត្តិធម៌" បានទៅអ្នកដែលហ៊ានអោយថ្លៃខ្ពស់ជាងគេបំផុត ។ ខណៈដែលចោរកំប៉ិកកំប៉ុកទទួលការកាត់ទោសអោយជាប់ពន្ធនាគារក្នុងរយៈពេលយូរ ឬការសងសឹកក្រៅច្បាប់ដោយហិង្សាលើជន

ល្មើសដែលប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរ បែរជាតែងតែត្រូវបានអនុញ្ញាតអោយគេចផុតពីច្បាប់តាមរយៈការដោះស្រាយក្រៅតុលាការជាមួយជនរងគ្រោះ ឬគ្រួសាររបស់ជនរងគ្រោះ ។ ជារឿយៗ នគរបាល ឬមន្ត្រីរដ្ឋអំណាចមូលដ្ឋានខ្លះដើរតួជាអ្នកសំរបសំរួលផ្សះផ្សាដោយសំណង និងយកកំរៃខ្លះសំរាប់ខ្លួនគេ ។

ការដោះស្រាយដោយការសំរួលគ្នានេះកើតមានជាធម្មតា ជាពិសេសក្នុងករណីរំលោភសេពសន្ថវៈ ។ ឧទាហរណ៍ នៅក្នុងខែកញ្ញា ឆ្នាំ២០០៥ យុវនារីអាយុ១៩ឆ្នាំម្នាក់នៅខេត្តកណ្តាល ត្រូវបានអ្នកជិតខាងរបស់នាង ចាប់រំលោភសេពសន្ថវៈ ។ យុវនារីនោះ បានសុំអោយអង្គការលីកាដូជួយដាក់ពាក្យបណ្តឹងទៅនគរបាល ។ ប៉ុន្តែ ជនល្មើសបានចរចាដំណោះស្រាយជាសំណងខុសច្បាប់ជាមួយជនរងគ្រោះ និងគ្រួសាររបស់នាង ។ ជនល្មើសបង់ប្រាក់សំណងអោយនាង ៧០០ដុល្លារ ហើយជាថ្នូរនឹងប្រាក់នេះ ជនរងគ្រោះបានដកពាក្យបណ្តឹងរបស់ខ្លួនពីនគរបាលវិញ ហើយបានប្រាប់លីកាដូថា នាងលែងត្រូវការជំនួយទៀតហើយ ។ នគរបាលបានទទួលប្រាក់ ១០០ ដុល្លារសំរាប់តួនាទីរបស់ខ្លួននៅក្នុងការចរចានោះ ។

ទំលាប់អនុវត្តបែបនេះ ពង្រឹងប្រពៃណីនិទ្ទណ្ឌភាពសំរាប់អ្នកដែលមានលុយ ធ្វើអោយអន្តរាយដល់ស្មារតីយុត្តិធម៌ នឹងជំរុញយ៉ាងសកម្មអោយមានការប្រព្រឹត្តល្មើសច្រំដែលៗ ។ ជនល្មើសរំលោភសេពសន្ថវៈម្នាក់ដែលធ្លាប់បានរំលោភម្តងហើយ ហើយរួចខ្លួនពីទណ្ឌកម្មធ្ងន់ធ្ងរ គឺថានឹងទំនងជារំលោភម្តងទៀត ។ ការបង់ប្រាក់សំណង២០០-៣០០ដុល្លារសំរាប់បទល្មើសនានា ដូចជា ការរំលោភសេពសន្ថវៈ ឬថែមទាំងការសំលាប់មនុស្សផងនោះធ្វើអោយថមថយការយល់ឃើញរបស់សាធារណជនចំពោះភាពធ្ងន់ធ្ងរនៃបទល្មើសទាំងនេះ និងចំពោះភាពមិនអាចរំលោភបាននៃជីវិតមនុស្ស ។ មន្ត្រីតុលាការ នគរបាល និងមន្ត្រីរដ្ឋអំណាចមូលដ្ឋានភាគច្រើន តែងតែខកខានមិនបានផ្តល់ការជួយគាំទ្រដល់ជនរងគ្រោះ ដែលមានបំណងស្វែងរកយុត្តិធម៌នៃការរំលោភសិទ្ធិមនុស្សឡើយ ។

ការខកខានមិនស៊ើបអង្កេតបទឧក្រិដ្ឋ ជាពិសេសបទឧក្រិដ្ឋដែលពាក់ពន្ធ័នឹងបុគ្គលិករដ្ឋ ឬបទឧក្រិដ្ឋដែលបណ្តាលមកពីហេតុផលនយោបាយ ជារឿយៗត្រូវបានគេបន្ទោសទៅលើការអសមត្ថភាព និងកង្វះធនធាននៅក្នុងជួរកំលាំងនគរបាល និងស្ថាប័នតុលាការ ។

វាជាការពិតដែលថា ស្ថាប័នទាំងពីរនេះខ្វះថវិកា ឧបករណ៍ និងការបណ្តុះបណ្តាលដើម្បីអនុវត្តការស៊ើបអង្កេតដែលស្មុគស្មាញ ប៉ុន្តែនេះក៏ជាលេសមួយផងដែរ ដើម្បីបិទបាំងកង្វះឆន្ទៈក្នុងការចុះស៊ើបអង្កេត [៣២] ។

នៅក្នុងករណីជាច្រើនដែលលីកាដូបានពិនិត្យតាមដាន នគរបាល ឬ ចៅក្រមស៊ើបអង្កេតខ្លះមានការខិតខំប្រឹងប្រែងតិចតួច ដើម្បីធ្វើការសាកសួរអោយបានត្រឹមត្រូវ ឬ មិនអើពើចំពោះភស្តុតាងដែលអាចនាំទៅរកការផ្តន្ទាទោសបុគ្គលអ្នកមានទ្រព្យសម្បត្តិ ដែលមានខ្នងបង្អែកច្រើន ។

[៣២] របាយការណ៍របស់តមនាង អ.ប.ស ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា គំរូនៅតែបន្តនៃនិទទ្ទភាព ខែតុលា ឆ្នាំ ២០០៥ ទំព័រ ៣៣។

ករណីដ៏លេចធ្លោនៃការកាត់ទោស ប៊ន សំណាង និង សុក សំអឿន កាលពីខែសីហា ឆ្នាំ២០០៥ ពីបទចោទប្រកាន់ថា បានសំលាប់មេដឹកសហជីពលោក ជា វិជ្ជា (ចូរមើលត្រង់ផ្នែកស្តីពីប្រពន្ធ័តុលាការខាងក្រោម) គឺគ្រាន់តែជាឧទាហរណ៍ថ្មីមួយ ដែលតុលាការទទួលយកចំលើយសារភាពដែលមានការចោទប្រកាន់ថា ធ្វើឡើងដោយការវាយដំ ហើយមិនអើពើនឹងចំលើយដោះសាររបស់ចុងចោទ ។ ប៉ុន្តែនៅកំរិតប្រចាំថ្ងៃ នគរបាលប្រឌិតភស្តុតាង ហើយចៅក្រមមួយចំនួនតែងតែមិនអើពើនឹងនីតិវិធី ឬមើលរំលងការខ្វះភស្តុតាងដែលអាចជឿជាក់បានទាំងស្រុងដើម្បីតាមយកកំរិតពីចុងចោទ ។ ការសន្មត់ជាមុនថាគ្មានទោសវាស្ថិតក្នុងការស៊ើបអង្កេត រហូតដល់ពេលដែលពិរុទ្ធភាពត្រូវបានបញ្ជាក់ច្បាស់លាស់លែងមានមន្ទិល គឺជាគោលគំនិតផ្លូវច្បាប់មួយដែលតែងតែត្រូវបានព្រងើយកន្តើយដោយតុលាករ។

ឧទាហរណ៍ នៅខេត្តពោធិ៍សាត់ បុរសម្នាក់បានទិញសាច់គោមួយដុំតូចនៅឯផ្សារក្នុងភូមិ ក្នុងឆ្នាំ ២០០៦។ នៅពេលនោះ គោរបស់អ្នកជិតខាងត្រូវបានចោរលួច ហើយបុរសនោះត្រូវបានចាប់ខ្លួនពីបទសង្ស័យថាបានលួចគោ ។ ទោះបីជាមានការតវ៉ាពីសមាជិក សហគមន៍ជាង ១០០នាក់ ដែលបានឃើញបុរសនោះទិញសាច់គោពីផ្សារ ក៏បុរសនោះត្រូវបានឃុំខ្លួនក្នុងពន្ធនាគារ លុះត្រាទាល់តែគាត់បង់ប្រាក់អោយមន្ត្រីចំនួន ៥០០ ដុល្លារ ដែលប្រាក់នេះមានចំនួនច្រើនជាងប្រាក់ចំណូលក្នុងមួយឆ្នាំរបស់ពលរដ្ឋខ្មែរភាគច្រើន ។ សំណុំឯកសារថ្នាក់ខេត្តរបស់លីកាដូពោរពេញទៅដោយករណីស្រដៀងៗគ្នានេះ ។

ទោះបីមានការសន្យាជាច្រើនពីសំណាក់រដ្ឋាភិបាលកម្ពុជាក្តី កង្វះនីតិរដ្ឋ និងវត្តមាននៃរចនាសម្ពន្ធ័អំណាចជាមូលដ្ឋាន ដែលអនុញ្ញាតអោយនិទ្ទណ្ឌភាពរីកធំធាត់ នៅតែគ្មានការផ្លាស់ប្តូរដដែលក្នុងរយៈពេល ១៣ឆ្នាំ ក្រោយពីកម្ពុជាងើបឡើងអះអាងថាជាប្រទេសប្រជាធិបតេយ្យ ។ មានភស្តុតាងតិចតួចនៃការថយចុះនូវអំពើពុករលួយនៅក្នុងតុលាការក្នុងអំឡុងពេលនេះ តែផ្ទុយទៅវិញអំពើពុករលួយរឹតតែមានភាពអាក្រក់ឡើងកាន់តែមានលក្ខណៈជាស្ថាប័នច្រើនឡើង និងទទួលយកជាទូទៅថា "ជារឿងធម្មតា" ។

រដ្ឋាភិបាលកម្ពុជា កងមានភារកិច្ចទទួលខុសត្រូវក្នុងការត្រួតត្រាកងកម្លាំងនគរបាល យោធា និងកងរាជអាវុធហត្ថ ។ ការដាក់ការត្រួតត្រាបែបនេះទាមទារនូវការបញ្ចប់ប្រពៃណី ដែលកងកំលាំងសន្តិសុខ ដែលជាប់ជំពាក់ទៅនឹងក្រុមឥស្សរជនកាន់អំណាចខ្លះ ហើយទាមទារនូវការអនុវត្តន៍កំណែទំរង់ប្រព័ន្ធយុត្តិធម៌ពិតប្រាកដ ។ សហគមន៍ អន្តរជាតិចាំបាច់ត្រូវតែទាមទារច្រើនជាងការសន្យាតែមាត់ទទេពីសំណាក់ រដ្ឋាភិបាលចំពោះបញ្ហានិទ្ទណ្ឌភាព ហើយការជំរុញកំណែទំរង់ច្បាប់ កំណើនសេដ្ឋកិច្ច និងទិសដៅអភិវឌ្ឍន៍មានតំលៃផ្សេង ទៀតនៅក្នុងប្រទេសមួយដែលពោរពេញដោយនិទ្ទណ្ឌភាព គឺដូចគ្នាទៅនឹងការសង់ផ្ទះពីសន្លឹកបៀដូច្នោះដែរ ។

## ករណីសិក្សា : អ្នកមានអំណាច និងអ្នកគ្មានអំណាច

ករណីមួយ ជាឧទាហរណ៍តំណាងអោយវប្បធម៌និទ្ទណ្ឌភាពឥតឈប់ឈររបស់អ្នកដែលមានខ្សែ និងមានអំណាចនៅក្នុងប្រទេសកម្ពុជា[៣៣] ។ សាច់ញាតិម្នាក់របស់មន្ត្រីជាន់ខ្ពស់ ត្រូវបានសាក្សីជាច្រើនបានឃើញថាបានបាញ់កាំភ្លើងទៅលើហ្វូងមនុស្ស ដែលចោមរោមមើលឧប្បត្តិហេតុគ្រោះថ្នាក់ចរាចរណ៍មួយនាខែតុលា ឆ្នាំ២០០៣ ដែលសំលាប់មនុស្សពីរនាក់ និងធ្វើអោយរបួស ៤នាក់ផ្សេងទៀត ។

ទោះបីមានសាក្សីបានឃើញផ្ទាល់ភ្នែកក៏ដោយ ជននោះត្រូវបានគេចោទប្រកាន់ពីបទសំលាប់មនុស្សដោយអចេតនា ខណៈដែលនគរបាល និងតុលាការទទួលយកការអះអាងដោយគ្មានសំអាងរបស់គាត់ថា បុគ្គលទីពីរដ៏អាថ៌កំបាំងម្នាក់ដែលគេរកមិនឃើញ គឺជាអ្នកទទួលខុសត្រូវចំពោះការសំលាប់មនុស្សនេះ ។ សាច់ញាតិរបស់ជនរងគ្រោះត្រូវបានគេសងប្រាក់សរុបចំនួន ៨.000 ដុល្លារ ហើយក្រោយមក បានបដិសេធមិនព្រមធ្វើកសិណសាក្សី ។ ចៅក្រម និងព្រះរាជអាជ្ញាត្រូវបានគេចោទប្រកាន់ជាទូទៅ ថាលំអៀងទៅរកចុងចោទ ហើយតុលាការក្រុងភ្នំពេញបានបើកសវនា ការវិនិច្ឆ័យទោសដោយមិនបានបើកចំហដល់សាធារណជន ហើយថែមទាំងមិនបានប្រកាសអោយដឹងទៀតផង ។ ទោះបីជាជននោះត្រូវបានកាត់ទោសអោយជាប់ពន្ធនាគាររយៈពេល ១៨ ខែ ក្នុងបទចោទប្រកាន់សំលាប់មនុស្សដោយអចេតនា នៅក្នុងសវនការដំបូងនេះក៏ដោយ ក៏ប៉ុន្តែទីបំផុតរាល់បទចោទប្រកាន់ទាំងអស់ត្រូវបានលើកលែងនៅក្នុងសវនាការដោយបិទទ្វារ និងមិនបានប្រកាសអោយដឹងមួយទៀតនៅឯតុលាការឧទ្ធរណ៍ នៅក្នុងខែសីហា ឆ្នាំ២០០៤ ។

និទ្ទណ្ឌភាពរបស់មនុស្សម្នាក់នេះ គឺជារឿងគួរអោយខ្លាចរអាខ្លាំងណាស់ នៅពេលដែលគេគិតពិចារណាទៅលើភាពឃោរឃៅរបស់ប្រព័ន្ធយុត្តិធម៌ចំពោះពលរដ្ឋខ្មែរសាមញ្ញ ។ គល់ វិនឡាយ ជាមនុស្សបន្ទាប់ដែលត្រូវបានកាត់ទោសនៅក្នុងតុលាការក្រុងភ្នំពេញ នៅថ្ងៃជាមួយគ្នានឹងការកាត់ទោសដំបូងលើករណីខាងលើនេះ ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគាររយៈពេល ៤ឆ្នាំ ពីបទចោទថាបានលួចលុយ ២.៧០០រៀល (0,៦៥ដុល្លារ) ក្រោយពីម្តាយរបស់គេពុំអាចបង់ប្រាក់ចំនួន ១.000ដុល្លារ ដែលគេបានទារជាថ្នូរនឹងការដោះលែងជននេះ[៣៤] ។

---

[៣៣] អង្គការលើកលែងទោសអន្តរជាតិ, "Cambodia: getting away with murder", Al Index ASA 23/010/2004 at http://www.unhcr.org/cgibin/texis/vtx/ home/opendoc.pdf?tbl=RSDCOI&id=42ae988a0

[៣៤] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក របាយការណ៍ប្រចាំត្រីមាស ខែកុម្ភៈ ឆ្នាំ២០០៥ ។

# ប្រព័ន្ធតុលាការ



អ្នកភូមិឫស្សីកែវ សម្តែងការខឹងសម្បារចំពោះអាជ្ញាធរ

ប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជា នៅតែមានលក្ខណៈពុករលួយ អសមត្ថ ភាព និងមានភាពលំអៀង ផ្នែកនយោបាយ ចំណែកឯការផ្លាស់ប្តូរស្ថាប័ន នាឆ្នាំ២០០៥ បាននាំអោយតុលាការ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័ននីតិប្រតិបត្តិកាន់តែខ្លាំងឡើងថែមទៀត ។ ប្រព័ន្ធតុលាការនៅតែត្រូវបានគេប្រើប្រាស់ជាឧបករណ៏របស់រដ្ឋាភិបាលនៅក្នុងរឿងក្តីនយោបាយ និងជាល្ខោននៃអំពើពុករលួយ ។

អង្គការលីកាដូជួយដល់ជនរងគ្រោះ ដោយសារការរំលោភសិទ្ធិមនុស្ស ក្នុង កិច្ចប្រឹងប្រែងរបស់ពួកគេ ដើម្បីស្វែងរកយុត្តិធមិតាមរយៈតុលាការ ។ ជាញឹកញយពួក គេជួបប្រទះនឹងអំពើពុករលួយ ភាពលំអៀងពីសំណាក់នគរបាល និងយោធាព្រមទាំង ភាពមិនអើពើចំពោះជនរងគ្រោះដោយសារបទឧក្រិដ្ឋ ដែលបង្កភាពតក់ស្លុត ដូចជាការ រំលោភសេពសន្ថវៈជាដើម ។ ទោះបីជាមានភស្តុតាងគ្រប់គ្រាន់នៅក្នុងករណីជាច្រើនក្តី មធ្យោបាយតាម ផ្លូវច្បាប់បានដោះស្រាយតែ ២១ ករណី ឬ ៦.១% ប៉ុណ្ណោះ ក្នុងចំណោម ៣៤៣ ករណីនៃការ រំលោភសិទ្ធិមនុស្សដែលបានរាយការណ៏មកលីកាដូនៅក្នុងឆ្នាំ២០០៥[៣៥] ។ នៅក្នុងករណីផ្សេងទៀត ការដោះស្រាយក្រៅតុលាការ ឬការសូកប៉ាន់អនុញ្ញាតអោយជនល្មើសអាចរួចខ្លួន ឬនគរបាល និងបុគ្គលិកតុលាការខកខានមិនបានដោះស្រាយអោយចប់ចុងចប់ដើម ហើយរឿងក្តីខ្លះត្រូវវង្វេងបាត់នៅក្នុងប្រព័ន្ធតុលាការ ។

ករណីដែលលេចធ្លោបំផុតចំនួនពីរនៃការមិនផ្តល់យុត្តិធមិ នៅក្នុងឆ្នាំ ២០០៥ គឺករណីលោក ជាម ច័ន្ទនី (ចូរមើលករណីសិក្សា) និងការកាត់ទោសបុរសពីរនាក់ពីបទធ្វើឃាតលើរូបមេដឹកនាំសហជីពសេរីកម្មករ លោក ជា វិជ្ជា នៅខែ មករា ឆ្នាំ ២០០៤ ។ ថ្វីត្បិតបើ ពុំមានភស្តុតាងជឿជាក់បានដែលបង្ហាញថា ជនជាប់ចោទទាំងពីរនាក់ គឺ ប៊ន សំណាង និង សុក សំអឿន មានជាប់ទាក់ទងនឹងករណីឃាតកម្មនេះឡើយ ។ ចំលើយសារភាពពីដំបូងរបស់ ប៊ន សំណាង ត្រូវបានដកវិញមួយថ្ងៃក្រោយមក ចំពេលដែលសាមីខ្លួនបញ្ជាក់អះអាងថានគរបាលបានវាយធ្វើបាបគំរាកំហែង និងសូកគាត់អោយផ្តល់ចំលើយសារភាព ។ ក្នុងអំឡុងពេលនៃការកាត់ទោសជនសង្ស័យទាំងពីរនាក់នេះ សាក្សីជាច្រើន នាក់បានឆ្លើយបំភ្លឺថា ប៊ន សំណាង កំពុងស្ថិតនៅកន្លែងផ្សេងនៅខណៈដែលអំពើឃាតកម្មបានកើតឡើង ។ បុគ្គលិកសិទ្ធិមនុស្សបានសំភាសមនុស្សមួយចំនួន ដែលអាចផ្តល់ចំលើយការពារសំរាប់ សុក សំអឿន ផងដែរ ប៉ុន្តែ ពួកគេមិនហ៊ានបង្ហាញខ្លួននៅក្នុងតុលាការទេ ដោយខ្លាចមាន

[៣៥] ក្នុងចំណោម ៣៤៣ករណី ដែលលីកាដូបានធ្វើការជាមួយ ក្នុងឆ្នាំ២០០៥ ២១ ករណី ត្រូវបានដោះស្រាយដោយផ្លូវច្បាប់ ១០៦ ករណីដោះស្រាយដោយ "មធ្យោបាយផ្សេងៗ" ២០១ ករណី កំពុងរង់ចាំការដោះស្រាយ និង ១៥ ករណី មិនត្រូវបានគេដោះស្រាយ ។

អំពើសងសឹក ។ ចៅក្រមស៊ើបអង្កេតទទួលបន្ទុករឿងក្តីនេះ លោក ហ៊ីង ធីរិទ្ធ បានលើកលែងការចោទប្រកាន់នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៤ ដោយសារខ្វះភស្តុតាង ។ ប៉ុន្មានថ្ងៃក្រោយមក ចៅក្រមរូបនេះត្រូវបានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបញ្ឈប់ពីមុខតំណែងនៅក្នុងតុលាការក្រុងភ្នំពេញ ហើយបន្ទាប់មកបានបញ្ជូនអោយទៅធ្វើការនៅខេត្តស្ទឹងត្រែង ។ សាលក្រមរបស់លោកក្នុងរឿងក្តីទាក់ទងនឹងឃាតកម្មលោក ជា វិជ្ជា នេះត្រូវបានច្រានចោលដោយចៅក្រមជំនុំជំរះ នៃតុលាការឧទ្ធរណ៍ លោក ធូ មុនី ។

អំពើទាំងនេះបានបញ្ជូនសញ្ញាមួយយ៉ាងច្បាស់ចំពោះចៅក្រមនានាថា បុរសទាំងពីរនាក់នេះត្រូវតែកាត់អោយជាប់ទោស បើទោះបីជាគ្មានភស្តុតាងដែលអាចជឿជាក់បាន និងមានចំលើយពីចុងចោទ ប៊ន សំណាង បញ្ជាក់អំពីការបង្ខិតបង្ខំ និងការសូកប៉ាន់ដែល នគរបាលបានផ្តល់អោយគាត់ក្តី ។ នៅក្នុងខែសីហា ឆ្នាំ២០០៥ ទាំងប៊ន សំណាង ទាំងសុក សំអឿន ត្រូវបានផ្តន្ទាទោសពីបទសំលាប់មនុស្ស និងកាត់អោយជាប់ពន្ធនាគាររយៈពេល ២០ឆ្នាំ ។ អង្គការសិទ្ធិមនុស្សជាតិ និងអន្តរជាតិជាច្រើនបានថ្កោលទោសលើសេចក្តីសំរេចនោះ ហើយប្អូនប្រុសរបស់លោក ជា វិជ្ជា គឺលោក ជា មុន្នី បានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈថា គាត់យល់ឃើញថា ឃាតករពិតប្រាកដមិនទាន់ត្រូវបានគេចាប់ខ្លួននៅឡើយទេ ។ ករណីធំៗ ដូចជាករណីមួយនេះគាំទ្របន្ថែមចំពោះការពិតដែលថានៅប្រទេសកម្ពុជា តុលាការទទួលរងការជ្រៀតជ្រែកពីផ្នែកនយោបាយ និងថានីតិរដ្ឋត្រូវបានអនុវត្តដោយគ្មានលក្ខណៈស្មើភាពគ្នា ។

ផលវិបាកនៃអំពើពុករលួយ និងអសមត្ថភាពរបស់ប្រព័ន្ធតុលាការ គឺថាពលរដ្ឋខ្លះបន្តអនុវត្តច្បាប់ដោយដៃខ្លួនឯងនៅក្នុងការផ្តន្ទាទោស នៅតាមដងផ្លូវ ដែលគេហៅថាជាការសំលាប់ដោយហ្វូងមហាជន ឬ "តុលាការរាស្ត្រ" ។

នៅក្នុងឆ្នាំ ២០០៥ លីកាដូ ប្រមូលបានព័ត៌មានអំពីករណីសំលាប់ដោយហ្វូងមហាជនចំនួន ១៧ករណីនៅទូទាំងប្រទេស[៣៦] ។ ករណី បែបនេះទំនងជាមានច្រើនជាងនេះទៀត ដែលត្រូវបានគេរាយការណ៍ ។ ជាធម្មតា ជនរងគ្រោះត្រូវបានចោទពីបទចោរកម្ម (ជាទូទៅ ចោរលួចម៉ូតូ ប៉ុន្តែកង់ក៏មានដែរ លួចគោក្របី និងក្នុងករណីមួយនោះ លួចជណ្តើរ) ត្រូវបានគេចាប់ខ្លួន និងវាយដំរហូតទាល់តែដាច់ខ្យល់ស្លាប់ ។ នៅក្នុងករណីចំនួន ៧ នគរបាលមានវត្តមាននៅកន្លែងកើតហេតុ ប៉ុន្តែមិនបានធ្វើអន្តរាគមន៍ទេ ហើយនៅក្នុងករណីមួយនៅខេត្តកំពង់ស្ពឺ ទាហានត្រូវបានគេរាយការណ៍ថា បានចូលរួមជាមួយអ្នកភូមិក្នុងការដេញតាម និងបាញ់សំលាប់ជនម្នាក់ ដែលគេសង្ស័យថាជាចោរ។ គ្មានអ្នកណាម្នាក់ក្នុងចំណោមមនុស្សដែលពាក់ព័ន្ធ នឹងការវាយប្រហារទាំងនេះត្រូវបាន គេនាំខ្លួនទៅកាត់ទោសឡើយនៅក្នុងឆ្នាំ ២០០៥ ។ ការសំលាប់ដោយហ្វូងមហាជន គឺជាការរំលោភដ៏ធ្ងន់ធ្ងរទៅលើសិទ្ធិក្នុងការទទួលបានការកាត់ទោសដោយយុត្តិធម៌ និងជាការបោះឆ្នោតដោយហិង្សាសំដែងការមិនទុកចិត្តទៅលើសមត្ថភាពរបស់នគរបាល និងតុលាការក្នុងការស្វែងរកយុត្តិធម៌ ។

[៣៦] ការិយាល័យត្រួតពិនិត្យរបស់លីកាដូ *របាយការណ៍ស្តីពីការសំលាប់ដោយមហាជន ឆ្នាំ២០០៥* របាយការណ៍ផ្ទៃក្នុង ។

នៅក្នុងខែឧសភា ឆ្នាំ ២០០៥ លេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានអាណត្តិដើម្បីការពារឯករាជ្យភាព និងបូរណភាពរបស់ប្រព័ន្ធតុលាការ ត្រូវបានផ្ទេរអោយស្ថិតនៅក្រោមអំណាចរបស់ក្រសួងយុត្តិធម៌ ។ ខណៈដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនដែលត្រូវបានចាត់ទុកថាឯករាជ្យ ឧត្តមក្រុមប្រឹក្សានេះមានសមាជិកភាគច្រើនបំផុតពាក់ព័ន្ធនឹងគណបក្សនយោបាយ ដែលស្ទើរតែជានិច្ចកាលធ្វើការតែងតាំងចៅក្រមណាដែលមានភក្តីភាពចំពោះគណបក្សរបស់ខ្លួន[៣៧] ការផ្ទេរលេខាធិការដ្ឋានត្រូវបានគេមើលឃើញថាជាការពង្រឹងអំណាចដោយស្ថាប័ននីតិប្រតិបត្តិ ។ លោកនាយករដ្ឋមន្ត្រីបានមានប្រសាសន៍ប្រាប់សារព័ត៌មានថា: "[ឥឡូវនេះ] លោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាផ្លូវចូលទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ដូច្នេះហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក៏បាននៅជិតលោកនាយករដ្ឋមន្ត្រីផងដែរ"[៣៨] ។ កង្វះនៃការបែងចែកអំណាចអោយដាច់រវាងស្ថាប័ននីតិប្រតិបត្តិ និងស្ថាប័នតុលាការធ្វើអោយប៉ះពាល់យ៉ាងខ្លាំងទៅលើឯករាជ្យភាពរបស់តុលាការនៃប្រទេសកម្ពុជា ។

គោលនយោបាយ "កណ្តាប់ដៃដែក" របស់លោកនាយករដ្ឋមន្ត្រីបានធ្វើអោយចៅក្រម និងក្រឡាបញ្ជីមួយចំនួនជ្រួលច្របល់ ក្នុងការធ្វើយ៉ាងណាអោយការងាររបស់គេនៅគង់វង្ស និងជាឧទាហរណ៍មួយទៀតនៃការជ្រៀតជ្រែករបស់អង្គនីតិប្រតិបត្តិនៅក្នុងកិច្ចការរបស់ប្រព័ន្ធតុលាការ ។ កាលពីខែមីនា ឆ្នាំ២០០៥ លោកនាយករដ្ឋមន្ត្រីបានប្រកាសយុទ្ធនាការមួយ ដើម្បីដោះស្រាយបញ្ហា ដែលចៅក្រមទទួលសំណូកអោយដោះលែងឧក្រិដ្ឋជនជាប់ចោទ ។ លោកបានសន្យាប្រើប្រាស់ "កណ្តាប់ដៃដែក" របស់លោក ដើម្បីសំអាតតុលាការ ។ ក្រោយមកមិនយូរប៉ុន្មានចៅក្រមបីរូប ព្រះរាជអាជ្ញាពីររូប និងក្រឡាបញ្ជីបីរូបត្រូវបានចោទប្រកាន់ពីបទពុករលួយ ។ បន្ថែមលើនេះទៀត ជនស៊ីវិលបីរូបត្រូវបានចោទប្រកាន់ពីបទសូកប៉ាន់ដែលទាក់ទង នឹងការចោទប្រកាន់ពីបទពុករលួយ ដែលត្រូវបានធ្វើឡើងប្រឆាំងនឹងបុគ្គលិកតុលាការ ។ នៅក្នុងខែសីហា ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមបានដាក់វិន័យព្រះរាជអាជ្ញាមួយរូបដោយការព្រមាន និងបានព្យួរការងារ ឬបណ្តេញចេញពីការងារនូវបុគ្គលិកតុលាការផ្សេងទៀត ។

ប៉ុន្មានខែក្រោយមក តុលាការខេត្តបាត់ដំបងបានកាត់ទោសបុគ្គលិកតុលាការទាំងអស់លើកលែងតែពីរនាក់គត់អោយជាប់ពន្ធនាគារ ដោយហាក់ដូចជាបង្ហាញអោយឃើញថា ប្រទេសកម្ពុជាកំពុងដោះស្រាយបញ្ហាអំពើពុករលួយក្នុងប្រព័ន្ធតុលាការ ។ ប៉ុន្តែ ការកាត់សេចក្តីនេះត្រូវបានធ្វើឡើងដោយ*កំបាំងមុខ* ហើយគ្មានការព្យាយាមណាមួយដែលត្រូវបានគេធ្វើឡើងដើម្បីចាប់ខ្លួនបុគ្គលិកទាំងនោះ ទោះបីនាំខ្លួនពួកគេទៅកាត់ទោស ឬនៅក្រោយការកាត់ទោសរួចក្តី ។ ការកាត់ទោសដោយកំបាំងមុខក៏បានផ្តល់នូវរឿងក្តីមួយដ៏សាមញ្ញសំរាប់

---

[៣៧] បញ្ជីឈ្មោះចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការជាន់ខ្ពស់ដទៃទៀតដែលចេញដោយក្រសួងយុត្តិធម៌ ឆ្នាំ ២០០៣ បានបង្ហាញយ៉ាងច្បាស់អំពីសមាជិកភាពគណបក្សនយោបាយរបស់មនុស្សម្នាក់ៗ : ១៨៩នាក់ ជាសមាជិកគណបក្សប្រជាជន ១១នាក់ ជាសមាជិកគណបក្សហ៊្វុនស៊ិនប៉ិច ។

[៣៨] ដោយ Prak Chanthul and Lee Berthiaume, *ការផ្លាស់ប្តូរអំណាច ដាក់ស្ថាប័នតុលាការស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាល* កាសែត ឌឹ ឃែមបូឌា ដេលី ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៥ ។

ការកាត់សេចក្តីឡើងវិញ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី២១ ខែ មេសា ឆ្នាំ ២០០៦ ។ អ្នកដែលត្រូវបានកាត់អោយជាប់ទោសពីមុនទាំងអស់ត្រូវបានលើកលែងការចោទប្រកាន់ ។ ផ្ទុយទៅវិញ សាលក្រមផ្តន្ទាទោសជនស៊ីវិលបីរូបពីបទផ្តល់សំណូក ត្រូវបានគេជឿជាក់ថា នៅចូលជាធរមាននៅឡើយ ហើយម្នាក់ក្នុងចំណោមជនស៊ីវិលទាំងបីរូបនោះ នៅកំពុងជាប់ពន្ធនាគាររយៈពេល ១៨ ខែនៅឡើយ[៣៩] ។ វាជាការពិបាកនឹងយល់ណាស់ថាតើហេតុ ដូចម្តេចបានជាការអោយសំណូកខុសច្បាប់ ប៉ុន្តែការទទួលសំណូកបែរជាស្របច្បាប់ទៅវិញនោះ ។

អ្វីដែលគួរអោយចាប់អារម្មណ៍នោះ គឺថា សាលក្រមវិនិច្ឆ័យទោសមន្ត្រីតុលាការទាំងនោះ ត្រូវបានគេប្រកាសនៅថ្ងៃទី ២១ ខែ ធ្នូ នៅមុនពេលកិច្ចប្រជុំដ៏សំខាន់នៃក្រុមពិគ្រោះយោបល់រដ្ឋាភិបាល-ម្ចាស់ជំនួយនាខែមីនា ស្តីពីកម្ពុជានៅពេលមួយ ដែលរដ្ឋាភិបាលប្រឈមមុខនឹងការពិនិត្យពិច័យដ៏តឹងតែងពីអន្តរជាតិចំពោះការឃុំខ្លួនអ្នករិះគន់ ។ ការកាត់សេចក្តីឡើងវិញនៅពេលក្រោយមក ដែលមន្ត្រីតុលាការត្រូវបានអោយរួចពីការចោទប្រកាន់នោះ ត្រូវបានធ្វើឡើងប្រហែលជា ៣សប្តាហ៍បន្ទាប់ពីកិច្ចប្រជុំម្ចាស់ជំនួយ ។

ផលវិបាកមួយនៃគោលនយោបាយ ដែលគេហៅថា "កណ្តាប់ដៃដែក" នោះ គឺថាឥឡូវនេះចៅក្រមមានអារម្មណ៍ថា ត្រូវតែធ្វើការកាត់ទោសអោយធ្ងន់ធ្ងរ និងមានលទ្ធភាពតិចតួចក្នុងការពិចារណាលើស្ថានទំងន់ទោស ឬការបន្ធូរបន្ថយទោស[៤០] ។ កត្តាមួយទៀត គឺការយល់ឃើញថា យុទ្ធនាការនេះបានបង្កើនអំណាចរបស់នគរបាល ដែលជាញឹកញយបានត្អូញត្អែរអំពីការដោះលែងជនសង្ស័យ ដែលពួកគេបានចាប់ខ្លួន ។

នេះគឺជាការគួរអោយព្រួយបារម្ភ ពីព្រោះអាចបង្ហាញថា ភស្តុតាងដែលផ្តល់ដោយនគរបាល ដែលជារឿយៗ គឺជាចំលើយសារភាព បានមកដោយការប្រើទារុណកម្ម ឬការគំរាមកំហែង នឹងត្រូវចៅក្រម ដែលមានការភ័យបារម្ភ ទទួលយកដោយគ្មានសង្ស័យ រឹតតែច្រើនថែមទៀត ។ ខណៈដែលកិច្ចប្រឹងប្រែង ដើម្បីបង្ក្រាបអំពើពុករលួយនៅក្នុងប្រព័ន្ធច្បាប់ត្រូវតែទទួលបានការស្វាគមន៍គោលនយោបាយ "កណ្តាប់ដៃដែក" បានពង្រឹងឥទ្ធិពលរបស់ស្ថាប័ននីតិប្រតិបត្តិ និងនគរបាលទៅលើប្រព័ន្ធតុលាការ ហើយបានធ្វើអោយប៉ះពាល់ដល់ឯករាជ្យភាពរបស់តុលាការដោយស្របពេលជាមួយគ្នានេះ មិនបានជួយដោះស្រាយបញ្ហាសំខាន់ៗនៅក្នុងប្រព័ន្ធតុលាការកម្ពុជាឡើយ ។

នៅក្នុងឆ្នាំ ២០០៤ សហគមន៍ម្ចាស់ជំនួយបានអំពាវនាវអោយមានការអនុម័តជាបន្ទាន់ នូវច្បាប់សំខាន់ៗចំនួន ៨ ក្នុងបំណងដើម្បី ធ្វើបច្ចុប្បន្នភាពទៅលើច្បាប់ដែលដាក់អោយប្រើប្រាស់ ក្នុងអំឡុងនៃរយៈ

---

[៣៩] Prak Chanthu, *មន្ត្រី ៧រូប ដែលកាត់ទោសក្រោម "កណ្តាប់ដៃដែក" ត្រូវបានលើកលែងការចោទប្រកាន់* កាសែតឌឺ ឃែមបូឌា ដេលីថ្ងៃទី២២-២៣ ខែមេសា ឆ្នាំ ២០០៦ ។

[៤០] គណៈកម្មការសិទ្ធិមនុស្សអាស៊ី *កម្ពុជា : ចៅក្រម និងព្រះរាជអាជ្ញាខេត្តរតនគិរី ត្រូវតែបណ្តេញចេញ និងកាត់ទោសពីបទពុករលួយ* ថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៦ ។

ពេលអន្តរកាលនាដើមទសវត្សរ៍ឆ្នាំ ១៩៩០ និងដើម្បីពង្រឹងស្ថាប័ន និងនីតិវិធីច្បាប់[៤១] ។ ការពិតទៅសហគមន៍អន្តរជាតិបានអំពាវនាវអោយមានការអនុម័តច្បាប់ទាំងនេះតាំងពីឆ្នាំ ១៩៩៤ មកម្ល៉េះ[៤២] ។ កង្វះនូវកំណែទំរង់ច្បាប់ត្រូវបានគេមើលឃើញថា មិនត្រឹមតែជាការបរាជ័យក្នុងការសំរេចគោលដៅអភិវឌ្ឍន៍ ដែលបានកំណត់ទុកប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាគោលនយោបាយដោយចេតនាមួយដើម្បីរក្សាទុកច្បាប់មួយចំនួន និងនីតិវិធី ដែលមានលក្ខណៈមិនច្បាស់លាស់ ដែលធ្វើអោយច្បាប់ត្រូវបានគេកនស្រាយដោយងាយស្រួល ។ ដំណើរយឺតយ៉ាវនៃការកែទំរង់ ក៏ធ្វើអោយតុលាការងាយស្រួលក្នុងការទទួលរងឥទ្ធិពល ហើយបញ្ហានេះនឹងនៅតែដូច្នេះ ប្រសិនបើរដ្ឋាភិបាលកម្ពុជាមិនអនុវត្តកិច្ចប្រឹងប្រែងពិតប្រាកដ ដើម្បីកែទំរង់ប្រព័ន្ធតុលាការ និងធានាឯករាជ្យភាពរបស់ប្រព័ន្ធតុលាការ ដូចដែលបានចែងនៅក្នុងរដ្ឋធម្មនុញ្ញទេនោះ ។

ជាងនេះទៅទៀត អំពើពុករលួយ និងកង្វះនូវធនធានច្បាប់សមស្រប នៅតែធ្វើអោយវិនិយោគទុនបរទេសស្របច្បាប់រយៈពេលវែង រុញរាក្នុងការមករកស៊ីនៅក្នុងប្រទេសកម្ពុជា ជាហេតុធ្វើអោយការអភិវឌ្ឍសេដ្ឋកិច្ចដែលចាំបាច់បំផុតសំរាប់ការកាត់បន្ថយភាពក្រីក្រមានការយឺតយ៉ាវ ។ បច្ចុប្បន្ននេះ កំណើនសេដ្ឋកិច្ចមានកំរិតខ្ពស់មួយភាគធំ ដោយសារមានការការពារពីអន្តរជាតិចំពោះវិស័យកាត់ដេរសំលៀកបំពាក់របស់ប្រទេសកម្ពុជា និងកំណើនវិស័យកសិកម្មតាមរដូវកាលប៉ុន្តែកត្តាទាំងនេះមិនអាចព្យាករណ៍ ហើយក៏មិនមាននិរន្តរភាពឡើយ ។

ខណៈដែលប្រទេសជិតខាងរបស់ខ្លួន សំរបខ្លួនចូលទៅក្នុងទីផ្សារពិភពលោក សេដ្ឋកិច្ចប្រទេសកម្ពុជាត្រូវបានធ្វើអោយខូចខាត ដោយសារអំពីពុករលួយ និងភាពគ្មានច្បាប់ ។

**ករណីសិក្សា : ជាម ច័ន្ទនី**

ឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍ដែលច្បាស់ក្រឡែតបំផុតនៃការដែលប្រព័ន្ធតុលាការដើរតួជាឧបករណ៍របស់រដ្ឋាភិបាល គឺករណី របស់សមាជិកសភាគណបក្សសំលេងជំទាស់ ឯ.ឧ.ជាម ច័ន្ទនី ។

នៅថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០៥ រដ្ឋសភាបានបោះឆ្នោតដកអភ័យឯកសិទ្ធិសមាជិកសភាបីរូបមកពីគណបក្សសមរង្ស៊ី ដោយបើកផ្លូវ ដល់ការកាត់ទោសពួកគេពីបទល្មើសព្រហ្មទណ្ឌ ។ ប្រធានគណបក្សសំលេងជំទាស់ គឺ ឯ.ឧ.សម រង្ស៊ី និងឯ.ឧ. ជា ប៉ូច បានចាកចេញពីប្រទេសភ្លាមៗ ដោយខ្លាចការចាប់ខ្លួន ។ នៅថ្ងៃដដែលនោះលោក ជាម ច័ន្ទនី ត្រូវបានចាប់ខ្លួនសួរចំលើយដោយអយ្យការយោធា និងឃុំខ្លួននៅក្នុងពន្ធនាគារយោធា បើទោះបីជាការពិតលោក ជាម ច័ន្ទនី ជាជនស៊ីវិលក៏ដោយ ។

---

[៤១] ច្បាប់សំខាន់ៗរួមមាន : ក្រមព្រហ្មទណ្ឌ ក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមស្តីពីនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ លក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីវិសោធនកម្មឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ប្រឆាំងនឹងអំពើពុករលួយ ។

[៤២] របាយការណ៍របស់តំណាងពិសេសនៃអគ្គលេខាធិការអ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា *គំរូនៅតែបន្តនៃនិទណ្ឌភាពនៅកម្ពុជា* ខែ តុលា ឆ្នាំ ២០០៥ ទំព័រ ១២-១៣ ។

លោកត្រូវបានគេចោទប្រកាន់ពីបទប៉ុនប៉ងបង្កើត "កងទ័ពខុសច្បាប់" ដោយសារលោកមានតួនាទីជាប្រធានគណៈកម្មាធិការរដ្ឋាភិបាលស្រមោលរបស់គណបក្ស សមរង្ស៊ី ទទួលបន្ទុកបញ្ហាការពារជាតិ ។ តំណែងគណៈរដ្ឋមន្ត្រីរដ្ឋាភិបាលស្រមោលបែបនេះ គឺជាការស្របច្បាប់ និងធម្មតានៅក្នុងគនបក្សសំលេងជំទាស់ក្នុងសភានៅទូទាំងពិភពលោក ។ ឯ.ឧ. ជាម ច័ន្ទនី ត្រូវបានបដិសេធការដោះលែងអោយនៅក្រៅឃុំបណ្តោះអាសន្ន និងត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មចាត់តាំង ( ទាក់ទងទៅនឹងការចោទប្រកាន់ពីបទបង្កើតកងកំលាំងប្រដាប់អាវុធខុសច្បាប់ និងបទឆបោក) ។

សវនាការកាត់សេចក្តី នៅថ្ងៃទី ៨ ខែ សីហា ដែលធ្វើឡើងនៅក្នុងតុលាការយោធា ត្រូវទទួលរងនូវការរិះគន់ជាច្រើន ។ ច្បាប់កម្ពុជា ចែងយ៉ាងច្បាស់ថា តុលាការយោធា គឺសំរាប់បុគ្គលិកយោធាដែលប្រព្រឹត្តបទល្មើសទាក់ទង នឹងតួនាទីរបស់ពួកគេនៅក្នុងជួរកងកំលាំងប្រដាប់អាវុធ ។ តុលាការនេះគ្មានយុត្តាធិការគតិយុត្តិដើម្បីកាត់ទោសឯ.ឧ. ជាម ច័ន្ទនី ឡើយ ។ ដោយគ្មានមូលដ្ឋានត្រឹមត្រូវ ហើយការកាត់ទោសបានក្លាយទៅជារឿងមិនត្រឹមត្រូវ ។ សាក្សីសំខាន់ឈ្មោះ ឡុង សេរី បានអះអាងនៅមុខតុលាការថា គាត់បានជ្រើសរើសសមាជិកបានចំនួន ៤០.០០០នាក់ ដោយផ្ទុយគ្នាទៅនឹងសេចក្តីថ្លែងជាលាយលក្ខណ៍អក្សរពីពេលមុនដែលថា គាត់បានជ្រើសរើសសមាជិក ៣០០ នាក់ ប៉ុន្តែទោះបីយ៉ាងដូច្នោះក៏ដោយ គាត់ពុំបានបង្ហាញភស្តុតាងអ្វីដើម្បីគាំទ្រចំលើយអះអាងរបស់គាត់ឡើយ ។

នៅពេលដែលចំលើយកសិណសាក្សីរបស់ ឡុង សេរី មានភាពច្របូកច្របល់ ឧត្តមសេនីយ៍ ន័យ ថុល ( ចៅក្រមជំនុំជំរះ និងជាប្រធានតុលាការយោធា) បានកាត់បន្ថយរយៈពេលនៃការចោទសួរដេញដោលរបស់មេធាវីចុងចោទចំពោះ ឡុង សេរី ហើយដាក់កំហិតអោយសាក្សីបួននាក់ផ្សេងទៀតផ្តល់ចំលើយកសិណសាក្សីសំរាប់ការកាត់ទោស តែពីរបីនាទីប៉ុណ្ណោះក្នុងម្នាក់ៗ ដោយមិនអនុញ្ញាតអោយមេធាវីរបស់ចុងចោទធ្វើការសាកសួរដេញដោលឡើយ ។ ក្រោយពីផ្តល់ចំលើយកសិណសាក្សីរួច សាក្សីសំខាន់រូបនេះបានទៅក្បែរសាក្សី ម្នាក់ទៀតនៅចំហៀងបន្ទប់តុលាការ ហើយពួកគេបានរិះគន់ ឡុង សេរី ថាប្រាប់រឿងមិនស៊ីសង្វាក់គ្នា ។ គេបានឮ ឡុង សេរី និយាយថា "កុំព្រួយ យើងនឹងទទួលបានលុយជាច្រើនសំរាប់ការឆ្លើយនេះ"[៤៣] ។ មេធាវីការពារក្តីអោយ ឯ.ឧ. ជាម ច័ន្ទនី ត្រូវបានបដិសេធម្តងហើយម្តងទៀតមិនអនុញ្ញាតអោយបង្ហាញសាក្សីរបស់ខ្លួន[៤៤] ។

នៅថ្ងៃបន្ទាប់ឯ.ឧ. ជាម ច័ន្ទនី ត្រូវបានកាត់អោយជាប់ទោសដោយជាប់ពន្ធនាគាររយៈពេល ៧ឆ្នាំ នៅក្នុងពន្ធនាគារយោធា ។ នៅក្រៅតុលាការ ព្រះរាជអាជ្ញាបានផ្តល់បទសំភាសន៍ដ៏ខ្លីបំផុតមួយដល់សារព័ត៌មាន ដោយគ្រាន់តែនិយាយថា : "កម្ពុជាមានច្បាប់របស់កម្ពុជា" ។ ដោយប្រឈមមុខនឹងការមិនគោរពច្បាប់ និងនីតិវិធីទាំងស្រុងបែបនេះ ឯ.ឧ. ជាម ច័ន្ទនី បានសំរេចចិត្តមិនប្តឹងឧទ្ធរណ៍ទេ ដោយគាត់បានប្រាប់មេធាវីរបស់លោកថា "គ្មានជំនឿ ឬសង្ឃឹមថាតុលាការនឹងផ្តល់យុត្តិធម៌ឡើយ" និងបានបន្ថែមទៀតថាការប្តឹងឧទ្ធរណ៍ "នឹងធ្វើអោយលោកនាយករដ្ឋមន្ត្រី ខឹង ហើយនឹងគ្មានលទ្ធផលល្អសំរាប់អនាគតខ្ញុំទេ" ។ ផ្ទុយទៅវិញគាត់បានស្នើសុំព្រះរាជទានទោសពីព្រះមហាក្សត្រ នរោត្តម សីហមុនី វិញ ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នាយករដ្ឋមន្ត្រីបានថ្លែងជាសាធារណៈថា ភរិយា ឯ.ឧ. ជាម ច័ន្ទនី ត្រូវតែប្រកាសថ្កោលទោស ឯ.ឧ. សម រង្ស៊ី ជាមុនសិន ទើបសំណើបែបនោះនឹងត្រូវបានពិចារណា ។ ការអត្ថាធិប្បាយនេះបង្ហាញអោយឃើញនូវកិរិតនៃការជ្រៀតជ្រែករបស់អង្គនីតិប្រតិបត្តិ នៅក្នុងករណីនេះ ។ នៅក្នុងរយៈពេលប៉ុន្មានខែ បន្ទាប់ពីការកាត់ទោស ឯ.ឧ. ជាម ច័ន្ទនី មេដឹកនាំគណបក្សសមរង្ស៊ី ឯ.ឧ. សម រង្ស៊ី ក៏ត្រូវបានកាត់ទោស ( *ដោយកំបាំងមុខ* ដោយគាត់បាន

[៤៣] កាសែត ភ្នំពេញប៉ុស្តិ៍ *ជាម ច័ន្ទនី : ការកាត់ទោស* ១២-១៥ សីហា ២០០៥

[៤៤] Ibid. ៧

ចាកចេញពីប្រទេស) ពីបទបរិហារកេរ្តិ៍ ហើយត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារ ១៨ ខែ ។ រឿងក្តីស្រដៀងគ្នានេះត្រូវបានគេធ្វើឡើងប្រឆាំងនឹងតំណាងរាស្ត្រគណបក្សសម រង្ស៊ី គឺលោក ជា ប៉ូច ។

ឯ.ឧ. ជាម ច័ន្ទនី ត្រូវបានអោយឈ្មោះថាជា "អ្នកទោសមនសិការ" ដោយអង្គការលើកលែងទោសអន្តរជាតិ (Amnesty International) ។ ក្រុមការងាររបស់អង្គការសហប្រជាជាតិស្តីពីការឃុំឃាំងដោយឥតច្បាប់ (WGAD) បានធ្វើការត្រួតពិនិត្យករណីនេះ ដោយធ្វើការសន្និដ្ឋានថា ការឃុំខ្លួនលោក គឺធ្វើឡើងដោយទំនើងចិត្ត ហើយបានរំលោភទាំងច្បាប់កម្ពុជា ទាំងច្បាប់អន្តរជាតិ និងបានស្នើអោយរដ្ឋាភិបាលកម្ពុជាចាត់វិធានការ ដើម្បីកែតំរូវស្ថានការណ៍នោះ[៤៥] ។ ដោយមានអន្តរាគមន៍ពីអន្តរជាតិដែលគាំទ្រឯ.ឧ.ជាម ច័ន្ទនី យ៉ាងខ្លាំងក្លា កិច្ចព្រមព្រៀងមួយដែលធ្វើឡើងរវាង ឯ.ឧ.សម រង្ស៊ី និងលោកនាយករដ្ឋមន្ត្រី បាននាំទៅរកការដោះលែង ឯ.ឧ.ជាម ច័ន្ទនី ដោយការលើកលែងទោសពីព្រះមហាក្សត្រ នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ដែលត្រូវជា ១ឆ្នាំ ៣ថ្ងៃ ក្រោយពីគាត់ត្រូវបានចាប់ខ្លួន ។ ទាំង ឯ.ឧ. ជាម ច័ន្ទនី និង ឯ.ឧ. សម រង្ស៊ី ត្រូវបានលើកលែងទោសដោយ ព្រះមហាក្សត្រ ហើយក្រោយមកអភ័យឯកសិទ្ធិសមាជិកសភាត្រូវបានផ្តល់អោយវិញជូនទាំងពីរ និងដល់តំណាងរាស្ត្រ ជា ប៉ូច ។

[៤៥] យោបល់របស់ WGAG លេខ ២៩/២០០៥ (កម្ពុជា) ថ្ងៃទី២៩ ខែវិច្ឆិកា ២០០៥

# តួនាទីរបស់សហគមន៍អន្តរជាតិ

ការបោះឆ្នោតឆ្នាំ ១៩៩៣ ដែលរៀបចំឡើងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (អ៊ុនតាក់) បានធ្វើអោយកម្ពុជាក្លាយជាការពិសោធន៍ដ៏ធំបំផុតរបស់ពិភពលោក នៅក្នុងការផ្លាស់ប្តូរពីស្ថានភាពក្រោយជំលោះ ឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ។ ចាប់តាំងពីពេលនោះមកសហគមន៍អន្តរជាតិបានផ្តល់វិភាគទានរាប់ពាន់លានដុល្លារ ជាលុយជំនួយដល់កម្ពុជា ដែលស្មើនឹងប្រហែលពាក់កណ្តាលនៃថវិកាសរុបរបស់ប្រទេសនេះ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ[៤៦] ។ ចំណែកខ្លះនៃលុយជំនួយទាំងនេះបានជួយប្រទេសកម្ពុជាក្នុងការអភិវឌ្ឍសង្គមដែលខ្ទេចខ្ទាំដោយសារសង្គ្រាមរបស់ខ្លួន និងមួយចំណែកខ្លះទៀតត្រូវបានចាយវាយខ្ជះខ្ជាយមិនប្រក្រតី ។ កំណែទំរង់ពិតប្រាកដមានលក្ខណៈយឺតយ៉ាវ ហើយសូចនាករសំខាន់ៗបង្ហាញនូវភាពរីកចំរើនតិចតួចបំផុតសំរាប់ការចាយវាយលុយជំនួយនេះ[៤៧] ។ការចូលរួមយ៉ាងខ្លាំងក្លារបស់ម្ចាស់ជំនួយជាពិសេសក្នុងផ្នែកបោះឆ្នោតជួយផ្តល់ភាពអាចជឿទុកចិត្តបានដល់រដ្ឋាភិបាលកម្ពុជា ។ ប៉ុន្តែទោះជា យ៉ាងនេះក្តី សហគមន៍អន្តរជាតិមានការទទួលខុសត្រូវក្នុងការប្រើប្រាស់អំណាចរបស់ខ្លួនអោយបានល្អ ដោយទទូចសុំអោយរដ្ឋាភិបាលកម្ពុជាធ្វើខ្លួនអោយក្លាយជាដៃគូអភិវឌ្ឍន៍ពិតប្រាកដ និងគិតគូរឡើងវិញអំពីអន្តរកម្មរវាងសិទ្ធិមនុស្ស និងការអភិវឌ្ឍ ។

ជាដំបូងគេត្រូវកត់សំគាល់ថា សហគមន៍អន្តរជាតិមិនមែនជាក្រុមមួយដែលមានសមាជិកដូចៗគ្នានោះទេ ។ ក្នុងចំណោមម្ចាស់ជំនួយពហុភាគី (ដូចជា ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី) ម្ចាស់ជំនួយទ្វេភាគី (ដែលមានប្រទេសជប៉ុន នៅជួរលើគេបំផុត) បេសកកម្មទូត ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងទីភ្នាក់ងារផ្សេងៗទៀត គឺតែងតែមានផលប្រយោជន៍នយោបាយ និងសេដ្ឋកិច្ចខុសៗគ្នា ។

ស្ថានទូតទទួលខុសត្រូវជាចំបងចំពោះប្រទេសរបស់ខ្លួន ហេតុដូច្នេះហើយពួកគេធ្វើអន្តរាគមន៍ស្រាលៗ ដើម្បីរក្សាទំនាក់ទំនងមិត្តភាពនៅក្នុងរដ្ឋាភិបាលកម្ពុជា ។ ប៉ុន្តែជារឿយៗ ពួកគេមានទំនាក់ទំនងជិតស្និទ្ធជាមួយកម្មវិធីជំនួយទ្វេភាគី ដែលចាយលុយរបស់អ្នកបង់ពន្ធ ។ ធនាគារអភិវឌ្ឍន៍ត្រូវតែចែកចាយប្រាក់ក្នុងទំរង់ជាជំនួយឥតសំណង និងកំចី ប៉ុន្តែ គួរតែពិចារណាទៅលើការណ៍ដែលថានៅថ្ងៃណាមួយ ប្រាក់កំចីទាំងនោះត្រូវតែសងវិញដោយប្រទេសកំពុងអភិវឌ្ឍន៍នេះ ។

[៤៦] ការវាយតំលៃជំនួយរបស់ធនាគារពិភពលោក ក្នុងបណ្តាឆ្នាំចន្លោះពីឆ្នាំ១៩៩៦ និង២០០១ បានអោយតួលេខ "លំហូរជំនួយពីខាងក្រៅ" ចំនួន ២,៧ពាន់លានដុល្លារ បើប្រៀបធៀបនឹងការចំណាយដែលធ្វើឡើងដោយរតនាគារ ២,១ពាន់លានដុល្លារ (របាយការណ៍ធនាគារពិភពលោក, កម្ពុជានៅលើផ្លូវបំបែក : ពង្រឹងភាពទទួលខុសត្រូវ ដើម្បីកាត់បន្ថយភាពក្រីក្រ ខែវិច្ឆិកា ឆ្នាំ២០០៤) ។

[៤៧] "គេត្រូវតែសន្និដ្ឋាន ដោយវិធានការសត្យានុម័តថា ភាពជឿនលឿនពិតជាមានតិចតួចបំផុត" Ian Porter នាយកធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា មានប្រសាសន៍ក្នុងអំឡុងពេលបិទកិច្ចប្រជុំក្រុមពិគ្រោះយោបល់ នាខែធ្នូ ឆ្នាំ២០០៤ ។

នៅក្នុងខែ មីនា ឆ្នាំ ២០០៦ កិច្ចប្រជុំក្រុមពិគ្រោះយោបល់រដ្ឋាភិបាលម្ចាស់ជំនួយ បានប្រកាសថា លុយជំនួយសំរាប់ឆ្នាំនេះ នឹងមានចំនួនសរុប ៦០១លានដុល្លារ ។ ចំនួននេះខ្ពស់ជាងការសន្យាផ្តល់អោយសំរាប់ឆ្នាំ ២០០៥ ដែលមានតែ ៥០៤ លានដុល្លារប៉ុណ្ណោះ ។ ការបង្កើនជំនួយត្រូវបានគេមើលឃើញថា ជាកាយវិការជឿទុកចិត្តលើប្រទេសកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសនេះ[៤៨] ។

ពេលវេលា គឺមានសារៈសំខាន់ ។ ប៉ុន្មានខែនៅមុនកិច្ចប្រជុំពិគ្រោះយោបល់នា ខែ មីនា ឆ្នាំ ២០០៦ គឺមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីស្ថានភាពនយោបាយ ជាពិសេសការចាប់អ្នករិះគន់រដ្ឋាភិបាលដាក់ពន្ធនាគារ ។ មេដឹកនាំបក្សប្រឆាំងស្ថិតនៅក្នុងភាពនិរទេសខ្លួន ដោយប្រឈមមុខនឹងទោសជាប់ពន្ធនាគាររយៈពេល ១៨ ខែ នៅក្នុងប្រទេសកម្ពុជា ហើយមេដឹកនាំជាន់ខ្ពស់មួយរូបនៃគណបក្សសមរង្ស៊ី ជាប់ពន្ធនាគារពីបទចោទប្រកាន់ដែលគ្មានមូលដ្ឋាន ។ ស្ថិរភាពនយោបាយមានភាពមិនប្រាកដប្រជា ហើយវិនិយោគិន (ទោះបីពួកគេជាក្រុមហ៊ុនអាជីវកម្ម ឬជាទីភ្នាក់ងារមនុស្សធម៌ក៏ដោយ) មិនចូលចិត្តចាក់លុយចូលក្នុងប៉ាន់ដែលធ្លុះឡើយ ។

ប៉ុន្តែនៅមុនពេលដែលកិច្ចប្រជុំពិគ្រោះយោបល់គ្រោងនឹងធ្វើឡើងបន្តិចកិច្ចប្រជុំនេះត្រូវបានពន្យារពេលរួចទៅ ហើយដោយសារចលាចលផ្នែកនយោបាយ ស្ថាប័ននីតិប្រតិបត្តិបានផ្លាស់ប្តូរពីជំហររឹងត្អឹងមកជាជំហរសំរុះសំរួលគ្នាវិញ ។ អ្នករិះគន់ពីបញ្ហាព្រំដែនត្រូវបានដោះលែងអោយនៅក្រៅឃុំបណ្តោះអាសន្ន (ទោះបីជាយ៉ាងនេះក្តី ការចោទប្រកាន់នៅមិនទាន់លើកលែងនៅឡើយ ហើយការដោះលែងអោយនៅក្រៅឃុំនេះត្រូវបានធានាដោយលោកនាយករដ្ឋមន្ត្រីផ្ទាល់) ហើយកិច្ចសំរុះសំរួលត្រូវបានធ្វើឡើងជាមួយឯឧត្តម សម រង្ស៊ី ដែលអនុញ្ញាតអោយមេដឹកនាំបក្សជំទាស់រូបនេះវិលត្រឡប់ចូលប្រទេសវិញ និងទទួលបានអភ័យឯកសិទ្ធិមកវិញសំរាប់ទាំងខ្លួនឯកឧត្តម និងសហសេវិក ។ ឯ.ឧ. ជាម ច័ន្ទនី បានទទួលព្រះរាជទានទោសពីព្រះមហាក្សត្រ តាមការស្នើសុំរបស់រដ្ឋាភិបាល ។ ប៉ុន្តែការដោះលែងពីពន្ធនាគារនូវមនុស្សដែលមិនគួរនឹងត្រូវនៅទីនោះ មិនគួរត្រូវបានគេចាត់ទុកជាភាពជឿនលឿនឡើយ ។ ផ្ទុយទៅវិញ វាជារឿងដើរទៅមុខមួយជំហានថយក្រោយពីរជំហានទៅវិញទេ ។

**"នៅក្នុងប្រទេសមួយចំនួន រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍របស់ខ្លួន មានក្បួនមួយ ។ រដ្ឋាភិបាលធ្វើពុតជាកែទំរង់ ហើយដៃគូអភិវឌ្ឍន៍របស់គេធ្វើពុតជាគាំទ្រកំណែទំរង់នោះ ខណៈដែលម្នាក់ៗខិតខំសំរេចរបៀបវារៈឯកជនផ្ទាល់រៀងៗខ្លួន ។ មនុស្សតិចតួចណាស់ដែលចាញ់បោកទង្វើ បែបនេះ ហើយមនុស្សតិចតួចបំផុតដែលចាញ់បោកទង្វើបែបនេះរយៈពេលយូរនោះ" ។**

នេះជាប្រសាសន៍របស់ Ian Porter នាយកនៃធនាគារពិភពលោកប្រចាំប្រទេសកម្ពុជា ក្នុងឱកាសបើកកិច្ចប្រជុំពិគ្រោះយោបល់ នាខែធ្នូ ឆ្នាំ២០០៤ ។

ភ្លាមៗនៅក្រោយកិច្ចប្រជុំពិគ្រោះយោបល់ ការវាយតំលៃពីស្ថានភាពសិទ្ធិមនុស្ស ដោយតំណាងពិសេសរបស់លោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា លោក **យ៉ាស្ហ ហ្គាយ** ដែលទើបនឹងត្រូវបានតែងតាំងថ្មី បានធ្វើអោយលោកនាយករដ្ឋមន្ត្រីមានភាពមិនសប្បាយចិត្តយ៉ាងខ្លាំង

[៤៨] "សំណើ គឺតែ ៥១៣លានដុល្លារ ប៉ុន្តែការសន្យាផ្តល់អោយមានចំនួនដល់ទៅ៦០១លានដុល្លារ ម្ចាស់ជំនួយបានកោតសរសើរលទ្ធផលដែលកម្ពុជាសំរេចបានក្រោមការដឹកនាំរបស់ហ៊ុន សែន" ប្រសាសន៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គាត ឈន់ ក្នុងសុន្ទរកថាបិទកិច្ចប្រជុំពិគ្រោះយោបល់ ឆ្នាំ ២០០៦ ។ កាសែតភ្នំពេញប៉ុស្តិ៍ *រដ្ឋាភិបាលកម្ពុជារាប់លុយ ៦០១លានដុល្លារ* ថ្ងៃទី ១០-២៣ មីនា ២០០៦ ។

ដែល ក្រោយមកបានប្រកាសជាសាធារណៈថា **យ៉ាស្ហ ហ្កាយ** គឺជា "មនុស្សឡប់"[៤៩] ហើយថាបុគ្គលិកនៃការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ថាជា "អ្នកទេសចររយៈពេលវែង" នៅក្នុងប្រទេសកម្ពុជាដែលត្រូវបានអត់ឱនអោយ ដោយសារតែពលរដ្ឋកម្ពុជារកលុយបានពីការជួលផ្ទះអោយពួកគេ ។ លោកនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា តំណាងពិសេសរបស់អង្គការសហប្រជាជាតិរូបនេះ នឹងមិនត្រូវអនុញ្ញាតអោយជួបជាមួយលោករដ្ឋមន្ត្រីខ្មែរទៀតឡើយ ។ ទោះបីជាទំនាក់ទំនងមុនៗរវាងលោកនាយករដ្ឋមន្ត្រីជាមួយតំណាងពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មិនដែលមានលក្ខណៈស្និទ្ធស្នាលក៏ដោយ តែការបង្ហាញនូវភាពមិនសប្បាយចិត្តលើកនេះ ជាចំណុចអវិជ្ជមានថ្មីមួយទៀត នៅក្នុងទំនាក់ទំនងរវាងរដ្ឋាភិបាល និងការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។

ជាថ្មីម្តងទៀត ការមិនចេះអត់ឱនរបស់រដ្ឋាភិបាលចំពោះការប្រឆាំង និងការរិះគន់ធ្វើអោយរដ្ឋាភិបាលមានឆន្ទៈបំភិតបំភ័យ ប្រមាថ និងកាត់ផ្តាច់ទំនាក់ទំនងជាមួយនឹងអ្នកទាំងឡាយនៅក្នុងសហគមន៍អន្តរជាតិដែលទទួលស្គាល់ជាសាធារណៈអំពីអំពើពុករលួយដ៏រីករាលដាល និងការរំលោភសិទ្ធិមនុស្ស ។

នៅក្នុងឆ្នាំ ២០០៤ ប្រជាពលរដ្ឋប្រមាណ ៣៥% រស់នៅក្នុងភាពក្រីក្រ[៥០] ។ ក្នុងបរិបទនេះ និយមន័យរបស់ធនាគារពិភពលោក អំពីកំរិតនៃភាពក្រីក្រសំរាប់ប្រទេសកម្ពុជា គឺ ១.៨២៦ រៀល (ស្មើនឹងប្រហែល ០.៤៥ ដុល្លារអាមេរិក) សំរាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ ដែល៨០%នៃទឹកប្រាក់នេះត្រូវបានចំណាយទៅលើម្ហូបអាហារ ។ នៅក្នុងខែឧសភា ឆ្នាំ២០០៦ តាមតំលៃទីផ្សារនៅក្នុងទីក្រុងភ្នំពេញ ប្រាក់ក្នុងចំនួននេះទិញបានអង្ករតែ ៥០០ ក្រាម (៦០០ រៀល) និងត្រី ០.១គីឡូ តែប៉ុណ្ណោះ (១.០០០ រៀល) ។ នៅក្នុងវិស័យ សុខាភិបាល អត្រាមរណៈរបស់ទារក (អាយុក្រោម ១ឆ្នាំ) បានកើនឡើងពី ៨០ករណី (ក្នុងទារកកើតរស់ចំនួន ១.០០០ នាក់) នៅក្នុងឆ្នាំ ១៩៩០ ដល់ ៩៧ករណី នៅក្នុងឆ្នាំ ២០០៤ ។ តួលេខសំរាប់អត្រាមរណៈរបស់កុមារ (អាយុដល់ ៥ឆ្នាំ) បង្ហាញអោយឃើញនូវកំណើនប្រហាក់ប្រហែលគ្នានេះដែរ ។ សូចនាករអភិវឌ្ឍន៍ដទៃទៀតបង្ហាញថា កម្ពុជាធ្វើអោយមានភាពជឿនលឿនចេញពីភាពក្រីក្រយឺតជាទីបំផុត[៥១] ។

មធ្យោបាយមួយដើម្បីលើកទឹកចិត្តអោយរដ្ឋាភិបាលអនុវត្តឆន្ទៈនយោបាយ ទៅលើទិសដៅអភិវឌ្ឍន៍ គឺត្រូវកំណត់បទដ្ឋានគំរូ ឬសូចនាករពិនិត្យការអនុវត្តដើម្បីវាយតំលៃលទ្ធផលដែលសំរេចបានប្រចាំឆ្នាំ។ បទដ្ឋានគំរូទាំងនេះ ត្រូវបានកំណត់នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់នាខែ ធ្នូ ឆ្នាំ ២០០៤ ហើយត្រូវបានអមជាមួយដោយពាក្យសំដីធ្ងន់ៗពីម្ចាស់ជំនួយ ដែលសំដែងនូវការចង់ឃើញអោយមានភាពជឿនលឿនពិតប្រាកដ ។

---

[៤៩] BBC News: *នាយករដ្ឋមន្ត្រីខ្មែរបដិសេធតំណាងពិសេស អ.ស.ប.* ថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០០៦ http://news.bbc.co.uk/1/hi/world/asia-pacific/4856718.stm

[៥០] ធនាគារពិភពលោកប៉ាន់ប្រមាណថា នៅក្នុងឆ្នាំ១៩៩៣/៩៤ កំរិតនៃភាពក្រីក្រមានប្រហែល ៣៩% ប៉ុន្តែតួលេខនេះ សំរាប់តែតំបន់ទាំងឡាយណា ដែលអាចចូលទៅដល់ និងទទួលរងផលប៉ះពាល់ដោយសារសង្គ្រាមស៊ីវិលតិច ។ ធនាគារពិភពលោកប៉ាន់ប្រមាណថា កំរិតភាពក្រីក្រទូទាំងប្រទេស នៅក្នុងឆ្នាំ១៩៩៣/៩៤ មានពី ៤០% ទៅ ៥០% ។ ធនាគារពិភពលោក *សំណួរចំលើយអំពីភាពក្រីក្រនៅកម្ពុជា* http://web.worldbank.org/WEBSITE/EXTERNAL/COUNTRIES/ ,EASTASIAPACIFICEXT/CAMBODIAEXTN/ 0,,contentMDK:20720 197-pagePK:141137-piPK:141127-theSitePK:293856,00.html

[៥១] Ibid.

ម្ចាស់ជំនួយខ្លះថែមទាំងបានភ្ជាប់លុយរបស់គេ ទៅនឹងសូចនាករត្រួតពិនិត្យការអនុវត្តន៍ទៀតផង ប៉ុន្តែម្ចាស់ជំនួយភាគច្រើនបំផុតមិនធ្វើដូច្នេះទេ ។ ភាគច្រើននៃបទដ្ឋានគំរូសំខាន់ៗ ដែលត្រូវបានកំណត់នៅក្នុងឆ្នាំ២០០៤ មិនត្រូវបានសំរេចឡើយ[៥២] ។ ដោយមិនគិតពីបញ្ហានេះ ម្ចាស់ជំនួយបន្តចាក់លុយទៅលើភាពជាដៃគូជាមួយរដ្ឋាភិបាល ដែលពីមួយឆ្នាំទៅមួយឆ្នាំ មើលទៅហាក់ដូចជានៅតែដដែល ។ លីកាដូ សូមលើកទឹកចិត្តអោយម្ចាស់ជំនួយ កំណត់សូចនាករត្រួតពិនិត្យការអនុវត្តន៍ និងទទូចសុំអោយមានភាពជឿនលឿនពិតប្រាកដដើម្បីសំរេចបាន គោលដៅទាំងនេះ ។

បន្ថែមទៅលើការខ្វះឆន្ទៈនយោបាយជាប្រវត្តិសាស្ត្រពីសំណាក់រដ្ឋាភិបាល គឺតួនាទីដែលមានការផ្លាស់ប្តូររបស់ប្រទេសចិន នៅក្នុងកិច្ចអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ។ នៅក្នុងខែ មេសា ឆ្នាំ ២០០៦ ប្រទេសចិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានាសំរាប់ជំនួយឥតសំណង និងប្រាក់កំចីសរុបប្រមាណ ៦០០លានដុល្លារ ដល់ប្រទេសកម្ពុជា ដែលស្ទើរតែស្មើគ្នានឹងចំនួនដែលសន្យាផ្តល់អោយនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ហើយលោកនាយករដ្ឋមន្ត្រីបានឆ្លៀតឱកាសថ្លែងអំណរគុណរដ្ឋាភិបាលប្រទេសចិន ចំពោះការដែលគ្មានកំណត់សូចនាករត្រួតពិនិត្យការអនុវត្តន៍ ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ដូច្នេះថា : "គ្មានការដាក់លក្ខខណ្ឌ គ្មានការកំណត់បទដ្ឋានគំរូ...ចិននិយាយតិច តែធ្វើច្រើន"[៥៣] ។ តួនាទីដែលកាន់តែរីកធំឡើងរបស់ប្រទេសចិនក្នុងឋានៈជា "ដៃគូដ៏ស្វាត់ស្វៀម" នៅក្នុងដំណើរការអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ព្រមទាំងក្នុងឋានៈជាវិនិយោគិនឯកជនដ៏ ធំអាចធ្វើអោយមានការផ្លាស់ប្តូរនូវតុល្យភាពនៃឥទ្ធិពលរវាងក្រុមពិគ្រោះយោបល់ និងម្ចាស់ជំនួយផ្សេងទៀត ។

នៅក្នុងវិស័យជាច្រើន ទិសដៅរបស់ទីភ្នាក់ងារអភិវឌ្ឍន៍ និងទិសដៅរបស់អង្គការដែលតស៊ូមតិផ្នែកសិទ្ធិមនុស្សមានភាពស្របគ្នា ។ អំពើពុករលួយដ៏រាលដាលដែលធ្វើអោយយឺតដល់ការលូតលាស់នៃមុខជំនួញ ក៏ជួយសំរួលដល់ទំលាប់និទ្ទណ្ឌភាព និងបង្កបង្កើតនូវភាពក្រីក្រ និងភាពទោមនស្សក្នុងចំណោមប្រជាពលរដ្ឋទូទៅ ។ បញ្ហានេះគឺប្រឆាំងដោយផ្ទាល់ នឹងទិសដៅជាច្រើនដែលបានលើកឡើងរបស់ម្ចាស់ជំនួយបរទេសរបស់ប្រទេសកម្ពុជា : លើកកំពស់នីតិរដ្ឋ និងកែលំអវិស័យសុខាភិបាល អប់រំ និងសេវាសំខាន់ៗផ្សេងៗទៀតដល់ប្រជាពលរដ្ឋកម្ពុជា ។ ឧទាហរណ៍ នៅស្របពេលដែលម្ចាស់ជំនួយចាក់លុយរាប់លានដុល្លារទៅលើការកែលំអប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា ការរឹបយកដីធ្លីពីសំណាក់អ្នកមានអំណាចបង្កើតនូវរលកថ្មីនៃឳពុកម្តាយកម្ពុជារងគ្រោះដោយសារភាពក្រីក្រដែលគ្មានលទ្ធភាពបញ្ជូនកូនអោយទៅរៀន ។ ស្ថិរភាព គឺជាគោលដៅរួមមួយទៀត ជាពិសេសក្រោយពីពេលមានសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំមក និងការខូចខាតដែលបានបំផ្លិចបំផ្លាញសង្គមកម្ពុជា ។ ប៉ុន្តែស្ថិរភាព នឹងមានទៅកើតលុះត្រាតែមាននីតិរដ្ឋ និងការទទួលស្គាល់សិទ្ធិមនុស្ស ។

---

[៥២] សូចនាករអភិវឌ្ឍន៍ផ្សេងៗ អាចរកមើលនៅលើវិបសាយទ៍របស់យូនីសេហ្វ (http://www.unicef.org/infobycountry /cambodia_statistics.html) និងធនាគារ ពិភពលោក (http://devdata.worldbank.org/external/cpprofile.asp?CCODE=KHM&PTYPE=CP)

# សេចក្តីសន្និដ្ឋាន

លីកាដូអះអាងបញ្ជាក់ថា នឹងមិនអាចមានស្ថិរភាពពិតប្រាកដឡើយ ប្រសិនបើ គ្មានសិទ្ធិមនុស្ស និងនីតិរដ្ឋទេនោះ ។ នៅពេលដែល អំណាចត្រូវបានប្រមូលផ្តុំនៅក្នុងដៃរបស់មនុស្សមួយចំនួនតូច ស្ថិរភាពអាចមាននិន្នាការទៅរកការកាន់កាប់អំណាចផ្តាច់ការដោយមនុស្សភាគតិចដែលរំលោភបំពាន និងកេងប្រវ័ញ្ចលើមនុស្សភាគច្រើន ។ នៅពេលដែលរដ្ឋាភិបាលរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំលទ្ធផលគឺមិនមែនជាបរិយាកាសនយោបាយដែលមានស្ថិរភាពឡើយ ប៉ុន្តែ គ្រាន់តែជាអវត្តមាននៃការជំតាស់ ដែលគេអាចព្យាបាន ។ ការបោះឆ្នោតដែលធ្វើឡើងក្នុងបរិយាកាសភ័យខ្លាចដែលបង្កឡើងដោយការវាយប្រហារ និងការបំភិតបំភ័យមិនអាចមានលក្ខណៈសេរី និងយុត្តិធម៌ឡើយ ទោះបីជាអ្នកទៅបោះឆ្នោតមានចំនួនប៉ុន្មានក៏ដោយ ។ សង្គមមួយដែលគ្មានសិទ្ធិក្នុងការទទួលបានយុត្តិធម៌ គឺជាសង្គមមួយដែលគ្មានការការពារពីឥទ្ធិពលនៃក្រុមប្រដាប់អាវុធ និងក្រុមមនុស្សដែលកាន់អំណាច ។ ដូចដែលបុគ្គលិកលីកាដូមួយរូបនៅខេត្តកំពត បាននិយាយកាលពីពេលថ្មីៗនេះ តើស្ថិរភាពអាចមានយ៉ាងដូចម្តេចទៅកើត នៅពេលដែលប្រជាពលរដ្ឋរស់នៅក្នុងភាពភ័យខ្លាចពីការចាប់រំលោភ និងការសំលាប់នោះ ?

និទ្ទណ្ឌភាពដែលតែងតែត្រូវគេផ្តល់ទៅអោយជនល្មើសរំលោភសិទ្ធិមនុស្ស ធ្វើអោយប៉ះពាល់ដល់នីតិរដ្ឋ ដូចគ្នានឹងអំពើពុករលួយ អសមត្ថភាព និងភាពលំអៀងផ្នែកនយោបាយនៅក្នុងប្រព័ន្ធតុលាការផងដែរ ។ ការកាន់តែកើនឡើងនូវចំនួនប្រជាពលរដ្ឋ ដែលបាត់បង់ទ្រព្យកម្មសិទ្ធិនៅក្នុងជំលោះដីធ្លី មិនបានបន្ថែមអ្វីដល់ស្ថិរភាពឡើយ ពួកគេគ្មានអ្វីសោះ ហេតុដូច្នេះហើយគ្មានអ្វី ដែលត្រូវបាត់បង់ទៀតនោះទេ ។ ស្ថិរភាពមិនអាចផ្តល់អោយដោយក្រុមមនុស្សដែលអស់សង្ឃឹម និងរស់នៅគោកយ៉ាកក្នុងភាពក្រីក្រឡើយ នេះគឺជាកត្តាដែលនាំអោយមានភាពរីករវរផ្នែកសង្គម នយោបាយ និងសេដ្ឋកិច្ច ។

លីកាដូសូមលើកទឹកចិត្តសហគមន៍អន្តរជាតិ ពិនិត្យមើលអោយបានហ្មត់ចត់ទៅលើស្ថិរភាព ដែលមើលឃើញតែពីខាងក្រៅ ហើយពិចារណាលើស្ថានភាពជាក់ស្តែងនៃសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងអ្វីដែលមានអត្ថន័យពិតប្រាកដចំពោះអនាគតរបស់ប្រទេសនេះ ។

# អនុសាសន៍

អនុសាសន៍ចំពោះសហគមន៍អន្តរជាតិ

**១. ពង្រឹងសាររបស់អន្តរជាតិ លើបញ្ហាសិទ្ធិមនុស្ស**

- កែលំអការសំរបសំរួលក្នុងចំណោមសហគមន៍អន្តរជាតិ និងទាមទារអោយរាជរដ្ឋាភិបាលកម្ពុជា បំពេញកាតព្វកិច្ចសិទ្ធិមនុស្ស អន្តរជាតិរបស់ខ្លួន នៅក្នុងសំលេងរួមគ្នាមួយ ជាពិសេស លើបញ្ហាសេរីភាពក្នុងការបញ្ចេញមតិ និងការប្រមូលផ្តុំ ។
- លើកឡើងពីបញ្ហាសិទ្ធិមនុស្សនៅថ្នាក់ការទូត និងនិយាយជាសាធារណៈប្រឆាំងនឹងករណីរំលោភសិទ្ធិមនុស្សធំៗ នៅក្នុងប្រទេសកម្ពុជា ។
- ធានាថា របៀបវារៈសិទ្ធិមនុស្សត្រូវបានភ្ជាប់ជាមួយនឹងគំនិតផ្តួចផ្តើមជាអន្តរជាតិដទៃទៀត ដោយដាក់បញ្ចូលការលើកកំពស់សិទ្ធិមនុស្សនៅក្នុងកិច្ចប្រឹងប្រែងអភិវឌ្ឍន៍ និងដោយធានាថាក្រុមហ៊ុនអន្តរជាតិដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ត្រូវគោរពតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។
- រក្សាការជួយគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីតាមដានការរំលោភសិទ្ធិមនុស្ស និងតស៊ូមតិអោយមានកំណែទំរង់ ក្នុងវិស័យសង្គម និងច្បាប់ ។
- បន្តកិច្ចពិភាក្សាជាទៀងទាត់ជាមួយអង្គការសង្គមស៊ីវិលកម្ពុជានិងផ្តល់ការគាំទ្រអ្នកការពារសិទ្ធិមនុស្ស ។
- ទទូចអោយរដ្ឋាភិបាលកម្ពុជាពង្រីក និងគាំទ្រអាណត្តិរបស់ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ព្រមទាំងលើកទឹកចិត្តដល់ការបំពេញការងារនៅក្នុងប្រទេសកម្ពុជារបស់តំណាងពិសេសអង្គការសហប្រជាជាតិ អ្នកធ្វើរបាយការណ៍ និងក្រុមការងារស្តីពីសិទ្ធិមនុស្ស ។

**២. កំណត់គោលដៅ និងសូចនាករត្រួតពិនិត្យការអនុវត្តអោយបានច្បាស់លាស់ និងទទូចអោយរដ្ឋាភិបាលកម្ពុជាអនុវត្តតាម គោលដៅ និងសូចនាករទាំងនោះ ដែលរួមមាន :**

**ក. កែលំអធម្មនុញ្ញភាពនៃច្បាប់**

- អនុម័តច្បាប់សំខាន់ៗ (ក្រមព្រហ្មទណ្ឌ ក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមស្តីពីនីតិវិធីព្រហទណ្ឌ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ លក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីវិសោធនកម្មឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្តីពីលក្ខន្តិកៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ប្រឆាំងនឹងអំពើពុករលួយ) ។
- ធានាថា បទបរិហារកេរ្តិ៍ព្រហ្មទណ្ឌត្រូវបានលុបចោល ។
- តំកល់ច្បាប់នាពេលបច្ចុប្បន្នដែលចែងថា តុលាការយោធាអាចកាត់ទោសតែបុគ្គលិកយោធាលុបចោលនូវមាត្រានៅក្នុងសេចក្តីព្រាងច្បាប់ដែលអនុញ្ញាតអោយតុលាការយោធាកាត់ទោសជនស៊ីវិល ។

### ខ. ពង្រឹងឯករាជ្យភាព និងបូរណភាពរបស់ប្រព័ន្ធតុលាការ

- កែប្រែច្បាប់ដែលកំណត់សមាសភាព និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រុមប្រឹក្សាធម្មនុញ្ញ ។

### គ. ធានាថា នីតិរដ្ឋត្រូវបានពង្រឹង និងអនុវត្តដោយស្មើភាពគ្នា

- ពង្រឹងការអនុវត្តនូវបទប្បញ្ញត្តិនៃច្បាប់ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈទូទៅសំរាប់បុគ្គលិកយោធា និងច្បាប់ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈ នៃមន្ត្រីរាជការ និងបង្កើតច្បាប់នគរបាលថ្មី ដើម្បីធានាអព្យាក្រឹតភាពរបស់មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ ។
- ធានាថា អព្យាក្រឹត្យផ្នែកនយោបាយរបស់ឧត្តមក្រុមប្រឹក្សាជាតិប្រឆាំងនឹងអំពើពុករលួយ ។
- អនុវត្តច្បាប់ភូមិបាល និងអនុក្រឹត្យដែលមានស្រាប់ទាក់ទងនឹងដីធ្លី ធ្វើសេចក្តីព្រាងអនុក្រឹត្យមួយដែលកំណត់តួនាទី និងដែនកំណត់របស់អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី និងពង្រឹងគណៈកម្មការសុរិយោដី ដើម្បីធានាអោយមានការកាន់កាប់ដីធ្លីដែលមានស្ថិរភាព ។
- អនុវត្តការស៊ើបអង្កេតអោយបានហ្មត់ចត់ និងនាំមកផ្តន្ទាទោស ចំពោះសមាជិកនៃកងកំលាំងប្រដាប់អាវុធ និងមន្ត្រីរដ្ឋាភិបាល ជាពិសេសមន្ត្រីជាន់ខ្ពស់ដែលពាក់ព័ន្ធនៅក្នុងការរំលោភសិទ្ធិមនុស្ស និងអំពើពុករលួយ ក្នុងនោះរាប់ទាំងការដោះស្រាយបទឧក្រិដ្ឋក្រៅតុលាការ ។
- លើកទឹកចិត្តកងកំលាំងនគរបាលអោយស៊ើបអង្កេតរកជនល្មើស ដែលបានប្រព្រឹត្តអំពើព្រួតវាយ សំលាប់ និងដាក់វិន័យចំពោះសមាជិក នៃកងកំលាំងសន្តិសុខ ដែលចូលរួមនៅក្នុង ឬដែលលើកទឹកចិត្តអោយមានអំពើបែបនេះ ។